ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលព្រៃឈើ

# គោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជា

# Guidelines on Private Forest Registration in Cambodia











នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន
- ឆ្នាំ ២០២១ -

# គោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជា

# Guidelines on Private Forest Registration in Cambodia


រៀបចំដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃឈើ និងព្រៃឯកជននៃរដ្ឋបាលព្រៃឈើ

#៥២-៥៤-៥៦ ផ្លូវលេខ ៣៨៤ សង្កាត់ទួលស្វាយព្រៃ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

Tel: (855-23) 214 651

Fax: (855-23) 212 201



គាំទ្រហិរញ្ញវត្ថុ: - អង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (The Asian Forest Cooperation Organization-AFoCO)

- សហគមន៍អឺរ៉ុប (European Union) តាមរយៈលេខាធិការដ្ឋានអនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វព្រៃ និងរុក្ខជាតិរងគ្រោះជិតផុតពូជ (Secretariat of the Convention on International Trade in Endangered Species of Wild Fauna and Flora-CITES)



©ឆ្នាំ២០២១ រដ្ឋបាលព្រៃឈើ

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់នៅក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (ឆ្នាំ២០១៦-២០៣០) ក្នុងការសម្រេចបាននូវគម្របព្រៃឈើ ៥០% នៅត្រឹមឆ្នាំ២០៣០ ដើម្បីការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ការប្រយុទ្ធប្រឆាំងនឹងឱនភាពដី និងភាពសឹករេចរឹលគុណភាពដី ព្រមទាំងការអភិរក្សធនធានជីវចម្រុះ ជាពិសេសធនធានសេនេទិចប្រភេទឈើកម្រ និងឈើមានតម្លៃពាណិជ្ជកម្ម។ ដើម្បីចូលរួមចំណែកសម្រេចបាននូវការអនុវត្តក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋបាលព្រៃឈើបានកំណត់សូចនាករនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយបង្កើនបរិមាណផលឈើដាំត្រូវបានប្រមូលពី ២០០.០០០ម$^{៣}$/ឆ្នាំ នៅឆ្នាំ២០១៩ ដល់ ៣០០.០០០ម$^{៣}$/ឆ្នាំ នៅឆ្នាំ២០២៣។

លើសពីនេះទៀត រដ្ឋបាលព្រៃឈើ បាននិងកំពុងអភិវឌ្ឍការងារដាំដុះព្រៃឈើឡើងវិញនៅលើផ្ទៃដីព្រៃរេចរឹល ដីនៅទំនេររបស់រដ្ឋ និងជំរុញឱ្យមានការចូលរួមដាំឈើនៅលើដីកម្មសិទ្ធិឯកជននូវប្រភេទឈើប្រណិត ឈើពាណិជ្ជកម្ម ដែលអាចធ្វើអាជីវកម្មក្នុងរយៈពេលវែង មធ្យម និងខ្លី សំដៅបង្កើតប្រភពផ្គត់ផ្គង់ផលឈើ និងឈើថាមពលចេញពីចម្ការឈើដាំ និងជួយបង្កើនកម្រិតជីវភាពរបស់ប្រជាជន ដើម្បីកាត់បន្ថយការពឹងផ្អែកអាស្រ័យផលឈើប្រភពចេញពីព្រៃធម្មជាតិ។

ដោយមានចែង ក្នុងច្បាប់ស្តីពីព្រៃឈើ អំពី “*ព្រៃឯកជន*” ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសស្តីពី “***វិធានព្រៃឯកជន***” ដើម្បីទទួលស្គាល់បុគ្គលដែលបានដាំឈើលើដីឯកជនផ្ទាល់ ឬលើដីព្រៃរបស់រដ្ឋដែលបានប្រគល់សិទ្ធិប្រើប្រាស់ មានសិទ្ធិថែរក្សា អភិវឌ្ឍ ប្រើប្រាស់ លក់ និងចែកចាយផលិតផលរបស់ខ្លួនបាន។ ក្រៅពីនេះ រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនជាកម្មសិទ្ធិករដីធ្លី ដែលបានដាំដុះឈើលើដីកម្មសិទ្ធិឯកជនដើម្បីបង្កើត និងចុះបញ្ជីជាព្រៃឯកជន នឹងទទួលបាននូវការលើកទឹកចិត្តពីរាជរដ្ឋាភិបាលកម្ពុជានូវអត្ថប្រយោជន៍ជាច្រើនដូចជា ការប្រឹក្សាលើបច្ចេកទេស ការបញ្ចុះអត្រាអាករនាំចេញលើមុខទំនិញប្រភេទឈើដាំ និងវត្ថុធ្វើពីឈើដាំ ការអនុគ្រោះបន្ថយ ៥០% នៃកាតព្វកិច្ចអាករនាំចេញសរុប លើការនាំចេញមុខទំនិញប្រភេទឈើដាំ និងការដាក់អាករនាំចេញជាបន្ទុករដ្ឋ ចំពោះការនាំចេញមុខទំនិញគ្រឿងសង្ហារឹម និងផលិតផលសម្រេចផ្សេងៗទៀតធ្វើពីឈើដាំក្នុងប្រទេស។

គោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជានេះ នឹងជាឯកសារបច្ចេកទេសសម្រាប់ជាមគ្គុទេសក៍ជួយកម្មសិទ្ធិករដីធ្លី ឬនីតិបុគ្គល ដែលមានបំណងចុះបញ្ជីព្រៃឯកជនរបស់ខ្លួនទាំងចម្ការឈើដាំ ឬដំណុះឈើដោយធម្មជាតិ ដើម្បីស្វែងយល់អំពីដំណើរការបង្កើត និងចុះបញ្ជីព្រៃឯកជន ចំណេះដឹង និងជំនាញក្នុងការថែទាំចម្ការព្រៃឯកជន និងអត្ថប្រយោជន៍នានាពីរាជរដ្ឋាភិបាល។

រដ្ឋបាលព្រៃឈើសង្ឃឹមយ៉ាងមុតមាំថា គោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជាជាប្រទីបក្នុងការដោះស្រាយចម្ងល់នានាអំពីការស្នើសុំបង្កើត និងដំណើរការចុះបញ្ជីព្រៃឯកជនសម្រាប់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច វិស័យឯកជន សហគមន៍ និងអាជ្ញាធរមូលដ្ឋានអាចប្រើប្រាស់ និងអនុវត្តបាន។ គោលការណ៍ណែនាំនេះ ជាសមិទ្ធផលដ៏វិសេសវិសាលនៃកិច្ចសហប្រតិបត្តិការ និងការគាំទ្រថវិការបស់រដ្ឋាភិបាលសាធារណៈរដ្ឋកូរ៉េ តាមរយៈអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (The Asian Forest Cooperation Organization-AFoCO) និងសហគមន៍អឺរ៉ុប (European Union) តាមរយៈលេខាធិការដ្ឋានអនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វព្រៃ និងរុក្ខជាតិរងគ្រោះជិតផុតពូជ (Secretariat of the Convention on International Trade in Endangered Species of Wild Fauna and Flora-CITES)។

**បណ្ឌិត កែវ អូម៉ាលីស្ស**

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ

# សេចក្តីថ្លែងអំណរគុណ

នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជននៃរដ្ឋបាលព្រៃឈើ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គ្រប់ភាគីពាក់ព័ន្ធ ដែលបានចូលរួមវិភាគទានជាគំនិតយោបល់ និងមតិល្អៗក្នុងការរៀបចំ *"គោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជា"* ជាពិសេសគម្រោង "The registration of small-scale private forest plantation in Cambodia" ដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលសាធារណៈរដ្ឋកូរ៉េ តាមរយៈអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (The Asian Forest Cooperation Organization-AFoCO) និងគម្រោង "Integrating the development of guidelines and incentives for piloting the establishment of small-scale private *Dalbergia* plantation" ដែលឧបត្ថម្ភថវិកាដោយសហគមន៍អឺរ៉ុប (European Union) តាមរយៈលេខាធិការដ្ឋានអនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វព្រៃ និងរុក្ខជាតិរងគ្រោះជិតផុតពូជ (Secretariat of the Convention on International Trade in Endangered Species of Wild Fauna and Flora-CITES) ក្នុងការគាំទ្រឱ្យមានការរៀបចំឯកសារគោលការណ៍សម្រាប់ការចុះបញ្ជីព្រៃឯកជននេះ។

*"គោលការណ៍ណែនាំស្តីពីការចុះបញ្ជី និងការអភិវឌ្ឍព្រៃឯកជន"* នេះ គឺជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់**លោក ឈាង ដានី** អនុប្រធានរដ្ឋបាលព្រៃឈើ ដែលតែងតែខិតខំ ស្វែងរកប្រភពថវិកាសម្រាប់ជួយលើការងាររៀបចំគោលការណ៍ណែនាំនេះ ចំណាយពេលវេលា និងគំនិតផ្តួចផ្តើមដ៏ល្អៗសម្រាប់ក្រុមការងាររៀបចំឯកសារនេះឡើងប្រកបដោយជោគជ័យ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិត កែវ អូម៉ាលីស្ស** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ និងថ្នាក់ដឹកនាំនៃរដ្ឋបាលព្រៃឈើ ដែលបានផ្តល់មតិណែនាំជាធាតុចូលសំខាន់ៗ គាំទ្រ និងលើកទឹកចិត្តដល់ក្រុមការងារក្នុងដំណើរការរៀបចំ *"គោលការណ៍ណែនាំ"* នេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកបណ្ឌិត លី ម៉េងស៊ាង** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន ដែលបានផ្តល់គំនិតផ្តួចផ្តើមដ៏ល្អៗ ចំណាយពេលវេលាក្នុងការដឹកនាំប្រជុំ ផ្តល់មតិណែនាំជាធាតុចូលសំខាន់ៗ គាំទ្រ និងលើកទឹកចិត្តដល់ក្រុមការងាររៀបចំ *"គោលការណ៍ណែនាំ"*នេះប្រកបដោយជោគជ័យ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ វិស័យឯកជន គ្រឹះស្ថានអប់រំ អង្គការជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធនានា ដែលបានចូលរួមជាមតិយោបល់ក្នុងការកែលម្អគោលការណ៍ណែនាំនេះ និងលើកឡើងនូវករណីនៃការដាំឈើនានាដែលគួរត្រូវបានបញ្ជាក់ឱ្យច្បាស់លាស់នៅក្នុងដំណើរការនៃការចុះបញ្ជីផងដែរ។

សូមថ្លែងអំណរគុណជាពិសេសដល់កិច្ចប្រឹងប្រែងរបស់ក្រុមការងារអនុវត្តគម្រោង "**The registration of small-scale private forest plantation in Cambodia**" និង គម្រោង "**Integrating the development of guidelines and incentives for piloting the establishment of small-scale private *Dalbergia* plantation**" រួមមានលោក គឹម សុបុណ្យ លោកស្រី លឹម សុភាព លោក ហ៊ត សុធា លោក សាយ ស៊ិនលី លោក ប៉ាង ផានិត លោក យី ណារ៉ុម លោក នាប កេង លោក ស៊ិន ចាន់តារ៉ា លោក ភួង សុភា លោក គង់ គង្គា កញ្ញា អ៊ូច ស៊ីនេត លោក ប៊ួរ វុឌ្ឍី និងលោក វណ្ណ វ័ន្ត។

ជាចុងបញ្ចប់ សូមថ្លែងអំណរគុណចំពោះលោក លោកស្រីថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងមន្ត្រីនៃនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន និងអ្នកជំនាញទាំងអស់ដែលបានចំណាយពេលវេលាក្នុងការពិនិត្យ និងផ្តល់មតិកែលម្អនានា ដើម្បីកែសម្រួលគោលការណ៍ណែនាំនេះឱ្យមានភាពល្អប្រសើរឡើង និងមានភាពងាយស្រួលសម្រាប់យកទៅអនុវត្ត។

# Executive Summary

Cambodia has the goal of maintaining at least 50% of its land under forest cover to contribute to the country's Sustainable Development Goals by 2030. In pursuit of this ambitious goal, the Forestry Administration has identified degraded forests and other degraded lands that are available for restoration and introduced initiatives for investing in the establishment of private forest plantations on state land by forging partnerships between various private sector entities. It has recently developed and obtained approval of the **Guidelines on Private Forest Registration**, as well. These guidelines are intended to provide policy support by means of incentives, including a 50% export tariff reduction on wood products derived from locally planted trees, to promote the extensive participation of the private sector in investing in tree plantations on private land.

The development of the Guidelines on Private Forest Registration has been supported by the European Union through the Secretariat of the Convention on International Trade in Endangered Species of Wild Fauna and Flora (CITES) under its project for "Integrating the Development of Guidelines and Incentives for Piloting the Establishment of Small-scale Private *Dalbergia* Plantations with the Determination of a Non-detriment Findings Report in Preah Vihear Province, Cambodia" and the Asian Forest Cooperation Organization (AFoCO) through its project on " The Registration of Small-scale Private Forest Plantations in Cambodia."

The Guidelines on Private Forest Registration consist of four chapters. The first provides a context by presenting critical information on the definition of private forests, as well as on supporting legislation, and eligibility. The second elaborates on the process applicants have to follow to register their private tree plantations. The third provides technical instructions on the development of plans for establishing private plantations. The fourth focuses on the harvesting of the trees that have been grown on private land, as well as on mechanisms for the monitoring and tracking of the produced wood by local Forestry Administration units. Each chapter is briefly described as follows:

***Chapter 1: Introduction***

Private forests are defined as plantations or trees that grow naturally on land that is registered and privately owned under state valid procedures and laws. Private forest refers to plantation established by natural persons or private legal entities who own land on their private land with the right to occupy in accordance with the land law and are registered as private forest according to the regulations of the Forestry Law and the Prakas No. 327 PRK dated 26 May 2017 on the Private Forest Rule.

The guidelines provide guidance to assist landowners or legal entities wishing to register their private forests, either plantations or natural plantations covering:

- the process of establishing and registering private forests;
- knowledge and skills in caring for private forest plantations;
- effective monitoring of the progress of responsible private forest management; and
- the importance of plantations and the potential of private plantations in improving the livelihoods of local people and communities, as well as contributing to socio-economic development and environmental protection.

In order to encourage participation in tree planting and development as plantations, Article 46 of the Forestry Law (2002) states that "Individuals who plant trees on private land or on state forest land that has been granted the right to use have the right to maintain, develop, use, sell and distribute their products," and subsequently, the Rules on private forests have been promulgated by Prakas of the Ministry of Agriculture, Forestry and Fisheries to encourage individuals to cultivate and maintain plantations.

The Prakas on the "Private Forest Rules" sets out the scope, requirements and procedures in the private forest registration process in Cambodia, classifying private forests according to the size of land planted or proposed, as well as outlines the many benefits that private forest owners receive and are encouraged. In this respect, the Forestry Administration would provide technical training services for afforestation and plantation management. Transportation of wood products originating from private forests to supply customers or the local market does not require a permit (LP). Prior to harvesting timber in a private forest plantation, the owner of the private forest shall notify the competent local forestry administration in writing the harvesting activities undertaken and be responsible for inspecting the amount of timber collected.

Private forest owners shall request their private forest logbook from the competent forestry administration of the relevant locality before harvesting the planted trees. Based on the Prakas on “Private Forest Rules”, private forest owners must record all harvesting information in their private forest logbook, such as the location of the harvested lot, the size of the harvested area, the amount of timber and the type of timber harvested. This logbook is useful for private forest owners to use instead of a transportation permit when transporting their products to customers in the local market.

However, Article 61 of the Forestry Law states that "the rules for granting the right to use state forest land for afforestation shall be determined by sub-decree", by which planting trees on degraded forest land where partnership in planting trees between the State and the private sector (Public Private Partnership (PPP) shall be authorized by the Royal Government of Cambodia as referred to a letter No. 120 S.C.N.K.S. dated 08 February 2017 of the Office of the Council of Ministers.

Who should use these guidelines?

- private forest owner;
- national and sub-national forestry administration officials; and
- NGOs and other stakeholders working in the field of private forest plantation.

Why do private forest owners have to use these guidelines?
The guidelines describe the process of establishing and registering private forests as well as explaining the technical standards to private forest owners for managing and developing their plantations. In addition, the guidelines will help private forest owners understand the incentives set out in the forest policies and legal frameworks more effectively regarding the implementation of forest management activities that contribute to the social environment and economic efficiency. Private forest owners can learn about the process of establishing and registering private forests described in these guidelines, completing application forms for registration, planting planning and recording in the logbook.

***Chapter 2: Practical Procedures for Registering Private Forests***
Under the guidelines, private forest plantations are categorized by area, each of which is distinguished by its own application form and place of submission.

There are four categories of private forest forests, as follows:

- household private forest plantations that consist of land areas of less than 10 hectares. The application form and the hard copies of associated documents under this category shall be submitted to the Forestry Administration Cantonment in the province where the private forest plantation is to be established;
- small-scale private forest plantations that consist of land areas that range from 10 to 100 hectares. The application form and the hard copies of associated documents under this category shall be submitted to the Provincial Department of Agriculture, Forestry and Fisheries in the province where the private forest plantation is to be established;

- medium-scale private forest plantations that consist of land areas that range from 100 to 1,000 hectares. The application form and the hard copies of associated documents under this category shall be submitted to the Forestry Administration at the central level in Phnom Penh; and
- large-scale private forest plantations that consist of land areas that are greater than 1,000 hectares. The application form and the hard copies of associated documents under this category shall be submitted to the Ministry of Agriculture, Forestry and Fisheries in Phnom Penh.

The documents required to be submitted with the application form are, namely, (i) a national identification card or passport; (ii) a land tenure certificate; and (iii) business patents if an applicant is a large entity or a company. The guidelines were developed to include sample attachments of application forms, verification and evaluation forms for inspecting the tree plantations in the field, a two-paged example of the forest registration certificate, and a logbook for recording harvesting data and other related information.

Natural persons or private legal entities who are interested in registering their private tree plantations may consult with the specialized officers of the Department of Plantation and Private Forest Development of the Forestry Administration or the specialized officers of the Forestry Administration division before applying for private forest registration.

There are three interrelated steps in the registration process**.** The initial step proceeds through the provision of general guidance to the filing out of the application form and submission of the required documents for reference and certification of legal acquisition. The second step establishes the process by which field verification and evaluation are conducted by appropriate authorities comprising of Forestry Administration officers from either or both the central and local levels. Finally, the third step is the issuance of the private forest registration certificate.

In the provision of private forest registration certificate, the Forestry Administration will provide a certificate of private forest registration to natural persons or legal entities who have applied for private forest registration at the request of the Provincial Department of Agriculture, Forestry and Fisheries (for household and small-scale private forest) and at the request of the specialized units under the supervision of the Forestry Administration (for medium- and large-scale private forest) with attached reports and records of field verification and evaluation. This certificate of private forest registration will be provided to the natural person or legal entity who has applied for private forest registration with the following conditions:

- land ownership certificate in accordance with the land law (original copy);
- the location of the proposed land is safe;
- in the case where the land is leased from the private sector on long term basis, the lease agreement and the consent from the property owner to register as a private forest in writing are needed; and
- planted trees make up at least 35% of the land cover.

In the case where the location of the application for registration has not met all the above conditions, the Forestry Administration has the authority to prepare a letter of notification to the natural person or private legal entity, as well as to recommend the documentation required and re-application.

The issuance of a certificate of private forest registration can be issued to the owner of the private land in the size of the area and/or the number of trees of equal value, depending on the actual situation in which the owner planted the tree, for example, for timber production or planting trees as a fence along borders.

If an applicant or a private tree plantation owner has complied with the requirements associated with both the legal acquisition and evaluation criteria for private tree plantations, a private forest certificate shall be issued to the applicant no later than two months after its initial submission. The application may be rejected, however, if the applicant fails to provide sufficient evidence associated with the legal title to the land and will be required to resubmit the application form. If an applicant lacks the required supporting documents or is unable to obtain satisfactory field verification, or is only partially able to comply with the field assessment criteria for their private plantation, the issuance of a private forest certificate will be suspended. The guidelines stipulate, as well, that in registering private forest plantations, owners are not required to have permits in their possession that are associated with the planned harvesting or transporting of wood products originating from their tree plantations, except for those products that are planned to be exported.

***Chapter 3: Preparatory Planning for Tree Plantation and Private Forests***

The establishment of private plantations and forests is the contribution of private forest owners, both physical and legal, in efforts to boost the national economy by creating a source of timber supply from plantations and reducing the pressure on the use of timber from natural forests. It will also create jobs, help increase incomes for the local communities and reduces poverty in rural areas. Planting plans prepared by individuals and legal entities could take into account a number of values, such as recreation, quality of the landscape, geography, biology and cultural heritage.

**Site selection for establishing tree plantation**

The selection of land for a tree-planting project is an important aspect that individuals or legal entities should study carefully before deciding to purchase or enter into joint venture to establish private plantations and forests, which should consider environmental and socio-economic factors. If private forests are established as commercial plantations, then they should be established where the soil and climatic conditions (quantity and distribution of rainfall) are suitable for the growth of the species. Establishing plantations or private forests, even small ones, is very expensive. Expenses for purchasing land, tools and equipment for planting trees, renting land, hiring workers, building roads, fencing, maintaining, protecting and transporting. If the private forest owner has a clear plan, the cost will be reduced.

Forest plantations can also be created as private forests in response to environmental and social benefits. Site assessment should begin at an early stage prior to land preparation, reviewing (i) soil conditions, flora and fauna using rapid assessment tools; (ii) status of land use in accordance with the land tenure system, not related to the state's permanent forest reserve or forest area of the protected area; (iii) economic analysis of the labor force; and (iv) effects of possible impacts such as water pollution, water scarcity and/or lack of water sources.

**Planning and factors to be considered**

After the site study process, planning for the establishment of a private commercial forest plantation should include an economic analysis to show that the plantation project will be profitable as a basis for investment decisions. The main points to be analyzed are, namely, (i) based on actual estimates of the area to be planted, excluding environmental costs and making actual estimates of financial revenues and establishment, maintenance and protection costs, etc.; (ii) consider the impact of topography and accessibility of harvesting and transportation costs using data from local plantation growth with similar conditions for estimating productivity and yields; and (iii) consider the potential risks of diseases, fires, pests, and other natural disasters.

Factors that should be considered in the preparation of plantations include (i) existence of plant systems, whether there is still potential for reforestation and usability? (ii) construction of roads and railways for private forest plantations over 10 hectares requires measures to prevent and control wildfires; (iii) preventive measures against diseases and pests; (iv) marketing plan and use

of wood, including land tenure and the legitimacy of the planting site, and whether there are still unresolved land tenure disputes before planting; and (v) plantation size where the larger the plantation, the smaller the cost per unit of land, so a change of land or a joint venture may be considered to reduce the cost of establishing a plantation.

Most of the planting work is done by farmers during the off-season. If the plantation is too large to handle, additional workers must be hired from outside. This problem is often encountered when preparing the plantation and when planting. Outsourcing must also provide accommodation.

Plantation planting and maintenance plan requires private forest owners to prepare in case the area of application for registration of private forest is more than 10 hectares.

Private forest owners need to inspect their plantations regularly after planting to monitor the growth of seedlings, seek advice or technical assistance from the competent forestry administration officials if necessary to ensure that plantations are of good quality and in accordance with technical specifications, and must cooperate with the competent forestry administration by reporting quarterly on the development status of their private plantations, including survival rates, growth maintenance activities, and other newly planted species (update private forest plantation data).

***Chapter 4: Harvesting and Monitoring Mechanisms for Tree Plantation and Private Forests***

This chapter describes the procedures for requesting harvesting of timber and the mechanism for inspecting plantations that private forest owners must perform, as well as how to record the activities of planting, maintenance and quantity of timber to be harvested. Record them in a logbook and report the harvesting activities and the amount of wood harvested to the competent Forestry Administration Officer.

**Harvesting operations**

Harvesting is a stage where private forest owners need to consider in advance a number of activities, such as harvesting operations, marketing and transportation to use, distribution and processing sites. At this stage, private forest owners need to consider harvest planning as follows:

- select a silvicultural system to implement;
- select the appropriate system of harvesting business;
- select equipment and materials for harvesting, hauling and processing; and
- plan the construction of tractors' roads and transportation.

Private forest owners who have registered private forests have the right to harvest, use and exploit non-timber forest products and processed wood products originating from their private forests by following the following rules:

Before forest harvesting, the private forest owners must report in writing to the competent Forestry Administration the location of the harvested lot, the area and the type of timber to be harvested, at least two weeks before the harvesting operation begins. In the case of private forests of 10 hectares or more, the owner of the private forest must attach a harvesting action plan, along with a map showing the location of the lot and the direction of transport to the market for use or distribution.

At the commencement of the harvesting operation, the private forest owner must record in his/her private forest logbook the location of the harvested plot, the size of the harvested area, the amount of timber or by-products collected and transported from his private forest plantation for processing. In the harvesting process, private forest owners must follow the Cambodian Code of Harvest Practices to ensure that their private forest harvesting business ensures:

- safety for workers during felling;
- minimize environmental and social impacts; and
- appropriate use of tractors and transportation that do not cause excessive damage to the road system or erosion.

The competent local forestry administration shall manage the records of each registered private forest and have the right to inspect any private forest logbook as necessary or in case of doubt to verify the harvesting activities and exploitation of private forest rights.

**Mechanisms for inspection of private plantations and forests**

After obtaining the certificate of registration of private forest, the applicant can request technical assistance, coordinate or cooperate with the Forestry Administration officials-in-charge of plantation maintenance. The private forest owner has to manage the plantation plantations based on the silvicultural techniques set forth in the private forest plantation plan or its private forest development plan until harvest time. Each private forest rights registered in accordance with the rules of the Prakas is responsible for keeping a record of all activities involved in the harvesting and exploitation of its plantations, including data on the amount of timber transported and processed, traded or used.

Inspections of plantations and private forests shall be carried out by the relevant private forest owners and/or professional officers of the competent forestry administration. The establishment of a mechanism to control private plantations and forests in this chapter is not meant to put pressure on private forest owners. Its aim is only to enable the Forestry Administration to have the authority to provide technical support services and technical guidance to owners through the provision of technical training services for afforestation and management of plantations from planting to the establishment of a complete plantation and harvest.

The information on the number of planted trees to be harvested at the time of harvest should be provided to the competent Forestry Administration Officer to enable the amount of timber to be deducted from the Forestry Administration data management system. This information shall be recorded in the logbook provided by the Forestry Administration along with the certificate of private forest registration, both of which will be used for the transportation of timber products from plantations to the market.

Private forest owners must monitor and record all activities related to private forest plantations, such as:

- date of tree planting, tree species, number of trees and/or area (hectares);
- cultivation data such as survival rate and growth in diameter, height and leaf expression;
- pruning and thinning of plantations, indicating the amount of timber removed and the amount of fruit harvested;
- quantity of fruit harvested by block and direction of distribution to market; and
- quantities and types of trees replanted or regenerated stumps.

Private forest owners are obliged to record in their logbook the activities of their private forest management for the monitoring, inspection, verification or technical support intervention by the competent forestry administration officer. Private forest activities are recorded on a monthly basis for each year of operation, as follows:

- records of the process of establishing a private forest, including activities ranging from site preparation, nursery, sapling, plantation, maintenance, application of silvicultural techniques on forest germination to the pre-harvest stage; and

- records of private forest harvesting process: including deforestation, pruning, hauling, piling and post-harvest forest cleaning, as well as information on transportation from stockpiles to warehousing markets, and the amount sold to factory or handicraft processing plants or exported.

**Monitoring and reviewing implementation**
The competent Forestry Administration Officer shall monitor and inspect the implementation of timber harvesting work in plantations and private forests, including the necessary documents such as certificates of private forest registration, information recorded in the ledger and logbook, harvest location, etc. If necessary, the competent Forestry Administration Officer would inspect the location of the harvesting block in the field if the private forest owner does not perform the work of recording or completing the data recording as instructed.

Samples of the following documents in the Khmer language are also provided in the guidelines:

- the application forms;
- the field verification and evaluation form;
- the front and back pages of the private forest certificate;
- the plan for establishing private forest; and
- the private forest logbook.

# មាតិកា

## ជំពូកទី ១ សេចក្តីផ្តើម


១.១ និយមន័យ ....1
១.២ គោលបំណង....1
១.៣ ក្របខណ្ឌច្បាប់ និងគោលនយោបាយ ....1
១.៣.១ ក្របខណ្ឌច្បាប់....1
១.៣.២ គោលនយោបាយ ....2
១.៣.៣ ផែនការយុទ្ធសាស្ត្រ ....3
១.៤ សិទ្ធិ និងអត្ថប្រយោជន៍នៃព្រៃឯកជន....3
១.៤.១ សិទ្ធិនៃកិច្ចដំណើរការដាំឈើ និងការប្រើប្រាស់ ....3
១.៤.២ ប្រតិបត្តិការដោយស្របច្បាប់....4
១.៥ ស្វែងយល់អំពីគោលការណ៍ណែនាំសម្រាប់ចុះបញ្ជីព្រៃឯកជន....4
១.៥.១ តើនរណាដែលត្រូវប្រើគោលការណ៍ណែនាំនេះ?....4
១.៥.២ ហេតុអ្វីម្ចាស់ព្រៃឯកជនត្រូវតែប្រើគោលការណ៍ណែនាំនេះ?....4
១.៥.៣ តើត្រូវប្រើគោលការណ៍ណែនាំនេះយ៉ាងណា?....5


## ជំពូកទី២ គោលការណ៍ណែនាំសម្រាប់ចុះបញ្ជីព្រៃឯកជន


២.១ ចំណាត់ថ្នាក់ និងលក្ខខណ្ឌតម្រូវនៃព្រៃឯកជន ....6
២.១.១ ចំណាត់ថ្នាក់....6
២.១.២ លក្ខខណ្ឌតម្រូវ....6
២.១.៣ ការប្រឹក្សាមុនដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន....6
២.២.១ ការដាក់ពាក្យស្នើសុំ....7
២.២.២ ការពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃ ....12
២.២.៣ ការផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន....16


## ជំពូកទី ៣ ការរៀបចំផែនការដាំឈើសម្រាប់ចម្ការឈើដាំ និងព្រៃឯកជន


៣.១ ការវាយតម្លៃទីតាំងដាំឈើ....22
៣.១.១ គោលការណ៍ ....22
៣.១.២ ការវិភាគចំណាយ....22
៣.១.២ ការវិភាគសេដ្ឋកិច្ច....23
៣.២ ការរៀបចំចម្ការឈើដាំ ....23
៣.៣ ការជ្រើសរើសទីតាំងសម្រាប់ដាំឈើ....23
៣.៣.១ ភាពដែលអាចចូលដល់ ....23
៣.៣.២ សណ្ឋានដី ....24
៣.៣.៣ កត្តាដី....24

៣.៤ ការធ្វើផែនការដាំដុះ........24
៣.៥ ការតាមដាន ពិនិត្យ និងវាយតម្លៃ........26
៣.៦ កំណត់ត្រា និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន........26

**ជំពូកទី ៤ ការប្រមូលផល និងយន្តការនៃការត្រួតពិនិត្យចម្ការឈើដាំ និងព្រៃឯកជន**

៤.១ ប្រតិបត្តិការប្រមូលផល........27
៤.១.១ មុនពេលប្រតិបត្តិការ........28
៤.១.២ ការចាប់ផ្តើមប្រតិបត្តិការប្រមូលផល........28
៤.២ យន្តការនៃការពិនិត្យចម្ការឈើដាំ និងព្រៃឯកជន........29
៤.២.១ ការតាមដាន និងពិនិត្យដោយសិទ្ធិវន្តព្រៃឯកជន........30
៤.២.២ ការកត់ត្រាចុះក្នុងសៀវភៅបន្ទុក........30
៤.៣ ការតាមដាន និងការពិនិត្យការអនុវត្ត........35
ឯកសារយោង........36

**បណ្ណាល័យសាស្ត្រ**

**ឧបសម្ព័ន្ធ**

# បញ្ជីពាក្យសរសេរកាត់

| | | |
|---|---|---|
| ហ.ត | : | ហិកតា |
| រ.ព | : | រដ្ឋបាលព្រៃឈើ |
| ខ.រ.ព | : | ខណ្ឌរដ្ឋបាលព្រៃឈើ |
| ក.ស.ក | : | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| AFoCO | : | អង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី<br>Asian Forest Cooperation Organization |
| CITES | : | លេខាធិការដ្ឋានអនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វព្រៃ និងរុក្ខជាតិរងគ្រោះជិតផុតពូជ<br>The Convention on International Trade in Endangered Species of Wild Fauna and Flora |
| LP | : | លិខិតអនុញ្ញាត<br>Letter of Permit |
| PPP | : | សហការដៃគូឯកជន និងរដ្ឋ<br>Public Private Partnership |
| SA | : | ការវិភាគភាពប្រែប្រួល<br>Sensitivity Analysis |

# ជំពូកទី ១
# សេចក្ដីផ្ដើម

## ១.១ និយមន័យ

ព្រៃឯកជនត្រូវបានកំណត់ ជាចម្ការឈើដែលបានដាំ ឬ ដើមឈើដុះដោយធម្មជាតិលើដីដែលបានចុះបញ្ជី និងផ្ដល់ជាកម្មសិទ្ធិឯកជនក្រោមនីតិវិធី និងច្បាប់រដ្ឋ។ ព្រៃឯកជនសំដៅដល់ចម្ការព្រៃដាំ ដែលបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន ដែលជាកម្មសិទ្ធិករដីធ្លីនៅលើដីកម្មសិទ្ធិឯកជនរបស់ខ្លួន ដោយទទួលសិទ្ធិកាន់កាប់ស្របតាមច្បាប់ភូមិបាល និងត្រូវបានចុះបញ្ជីទទួលស្គាល់ជាព្រៃឯកជនស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីព្រៃឈើ និងប្រកាសស្ដីពីវិធានព្រៃឯកជន។ វាក្យសព្ទសំខាន់ៗដែលបានប្រើក្នុងគោលការណ៍ណែនាំនេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមនៃគោលការណ៍ណែនាំនេះ។

## ១.២ គោលបំណង

គោលការណ៍ណែនាំនេះ គឺជាឯកសារបច្ចេកទេសសម្រាប់ជាមគ្គុទេសក៍ជួយកម្មសិទ្ធិករដីធ្លី ឬ នីតិបុគ្គលដែលមានបំណងចុះបញ្ជីព្រៃឯកជនរបស់ខ្លួនទាំងចម្ការឈើដាំ ឬ ដំណុះឈើដោយធម្មជាតិ ដើម្បីស្វែងយល់អំពី៖

- ដំណើរការនៃការបង្កើត និងចុះបញ្ជីព្រៃឯកជន
- ចំណេះដឹង និងជំនាញក្នុងការថែទាំចម្ការព្រៃឯកជន
- ប្រសិទ្ធភាពនៃការតាមដានវឌ្ឍនភាពនៃការគ្រប់គ្រងព្រៃឯកជនប្រកបដោយការទទួលខុសត្រូវ
- សារប្រយោជន៍នៃចម្ការឈើដាំ និងសក្ដានុពលនៃចម្ការព្រៃដាំឯកជនក្នុងការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន ព្រមទាំងចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងការគាំពារបរិស្ថាន។

## ១.៣ ក្របខណ្ឌច្បាប់ និងគោលនយោបាយ

### *១.៣.១ ក្របខណ្ឌច្បាប់*

ច្បាប់ស្ដីពីព្រៃឈើឆ្នាំ២០០២ បានចែងអំពីការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សព្រៃឈើ ដើម្បីធានាដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពសម្រាប់សង្គម សេដ្ឋកិច្ច និងបរិស្ថានរួមទាំងការអភិរក្សជីវចម្រុះ និងបេតិកភណ្ឌវប្បធម៌។ ដើម្បីជំរុញឱ្យមានការចូលរួមដាំដើមឈើ និងអភិវឌ្ឍជាចម្ការឈើដាំ នៅក្នុងច្បាប់ស្ដីពីព្រៃឈើ មាត្រា ៤៦ ចែងថា "បុគ្គលដែលបានដាំដើមឈើលើដីកម្មសិទ្ធិឯកជនផ្ទាល់ ឬលើដីព្រៃរបស់រដ្ឋដែលបានប្រគល់សិទ្ធិប្រើប្រាស់ មានសិទ្ធិថែរក្សា អភិវឌ្ឍ ប្រើប្រាស់ លក់ និងចែកចាយផលិតផលរបស់ខ្លួនបាន" និង "វិធានស្ដីពីព្រៃឯកជនត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីជំរុញលើកទឹកចិត្តដល់បុគ្គលក្នុងការដាំដុះ និងថែទាំចម្ការព្រៃឈើ"។

ច្បាប់ភូមិបាលឆ្នាំ២០០១ បានកំណត់នូវដីដែលជាកម្មសិទ្ធិឯកជន និងកម្មសិទ្ធិរបស់រដ្ឋ (ដីឯកជនរបស់រដ្ឋនិងដីសាធារណៈរបស់រដ្ឋ) និងប្រព័ន្ធផ្លូវទឹកធម្មជាតិត្រូវបានកំណត់ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋ។ នៅក្នុងសទ្ទានុក្រមនៃច្បាប់ភូមិបាល បានកំណត់នូវនិយមន័យនៃពាក្យ "**កម្មសិទ្ធិ**" និង "**ភោគៈ**" ដូចខាងក្រោម៖

- កម្មសិទ្ធិ ជា "សិទ្ធិដែលមានពេញលេញលើចលនវត្ថុ ឬអចលនវត្ថុ។ សិទ្ធិនេះមានបីគឺសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែង"។

- ភោគៈ ជា "សិទ្ធិដែលជនម្នាក់ៗមានលើទ្រព្យណាមួយជាបណ្តោះអាសន្ន មិនទាន់ស៊ប់ជារបស់ខ្លួនប្រាកដទេ។ "ភោគៈ" ជាពាក្យផ្ទុយនឹងកម្មសិទ្ធិ ដែលសិទ្ធិពេញបរិបូរណ៍របស់ជនម្នាក់ៗ លើទ្រព្យណាមួយ ឧទាហរណ៍៖ ដីមានប្លង់សុរិយោដី ជាដីកម្មសិទ្ធិ ឯដីមិនទាន់មានប្លង់កម្មសិទ្ធិ គឺជាដីភោគៈ"។

ប្រកាសស្តីពី "វិធានព្រៃឯកជន" បានកំណត់វិសាលភាព លក្ខខណ្ឌតម្រូវ និងនីតិវិធីនៅក្នុងដំណើរការចុះបញ្ជីព្រៃឯកជននៅកម្ពុជា។ ប្រកាសនេះ បានកំណត់ចំណាត់ថ្នាក់ព្រៃឯកជនទៅតាមទំហំផ្ទៃដីដែលដាំឈើ ឬ ស្នើសុំបង្កើត ព្រមទាំងបង្ហាញនូវអត្ថប្រយោជន៍ជាច្រើនដែលម្ចាស់ព្រៃឯកជនទទួលបាន និងត្រូវបានលើកទឹកចិត្ត។ ដោយឡែកការប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ នៅក្នុងច្បាប់ស្តីពីព្រៃឈើ មាត្រា ៦១ ចែងថា "វិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ ត្រូវកំណត់ដោយអនុក្រឹត្យ" ។

### ១.៣.២ គោលនយោបាយ

សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីគោលនយោបាយវិស័យព្រៃឈើជាតិឆ្នាំ២០០២ បានជំរុញឱ្យប្រជាជនកម្ពុជា និងវិស័យឯកជនចូលរួមអភិរក្សព្រៃឈើក្នុងគោលបំណងធានាសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងជំរុញឱ្យមានការវិនិយោគដាំឈើគ្រប់រូបភាពដូចជាការដាំដោយបុគ្គលលក្ខណៈគ្រួសារ ដាំដោយឯកជនលើសម្បទានដីសេដ្ឋកិច្ច និងដៃគូសហការរវាងរដ្ឋជាមួយនឹងឯកជនជាដើម ដើម្បីបង្កើតប្រភពនៃការផ្គត់ផ្គង់ឈើក្នុងស្រុក និងនាំចេញពីចម្ការឈើដាំជំនួសប្រភពផ្គត់ផ្គង់ឈើចេញពីព្រៃធម្មជាតិ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកទឹកចិត្តដល់ការងារដាំឈើមានដូចជា៖

- ការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរេចរឹល ឬ ដីទំនេររបស់រដ្ឋសម្រាប់ការដាំឈើ (អនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨ ស្តីពីវិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ)។
- ការអនុញ្ញាតគោលការណ៍ដាំឈើលើដីព្រៃឈើរេចរឹលដោយសហការដៃគូរវាងរដ្ឋជាមួយនិងវិស័យឯកជន (Public Private Partnership-PPP) (លិខិតលេខ ១២០សជណ.កស ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) ជាគោលការណ៍គឺរាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យធ្វើការដាំដុះដើមឈើលើផ្ទៃដីព្រៃឈើដែល រងការធ្វើអាជីវកម្មកន្លងមក ផ្ទៃដីដែលមានភាពរេចរឹល និងលើដីទំនេររបស់រដ្ឋ។
- ជំរុញការបង្កើនកម្រិតជីវភាពរបស់សហគមន៍មូលដ្ឋាន ដើម្បីកាត់បន្ថយការពឹងផ្អែកអាស្រ័យផលឈើ សំដៅបង្កើតប្រភពផ្គត់ផ្គង់ផលឈើ និងឈើថាមពលចេញពីចម្ការឈើដាំ (ទិសដៅយុទ្ធសាស្ត្រដែលបានកំណត់ក្នុងទស្សនវិស័យគ្រប់គ្រងព្រៃឈើរយៈពេលវែងតាមលិខិតលេខ ១២១១សជណ.សក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី)។
- ការបញ្ចុះអត្រាអាករនាំចេញលើមុខទំនិញប្រភេទឈើដាំ និងវត្ថុធ្វើពីឈើដាំ ដើម្បីលើកទឹកចិត្តវិនិយោគិនដាំឈើ (លិខិតលេខ ១៧០៤សជណ.សធ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) ដូចជា៖
  - អនុគ្រោះបន្ថយ៥០% នៃកាតព្វកិច្ចអាករនាំចេញសរុប លើការនាំចេញមុខទំនិញប្រភេទឈើដាំក្នុងប្រទេស
  - ដាក់អាករនាំចេញជាបន្ទុករដ្ឋចំពោះការនាំចេញមុខទំនិញគ្រឿងសង្ហារឹម និងផលិតផលសម្រេចផ្សេងៗទៀតធ្វើពីឈើដាំក្នុងប្រទេស
  - អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ជាក់លើអាជ្ញាបណ្ណនាំចេញនូវឈ្មោះវិទ្យាសាស្ត្រ និងឈ្មោះពាណិជ្ជកម្មរបស់ឈើ និងត្រូវបញ្ជាក់ថា ជា "ប្រភេទឈើដាំក្នុងប្រទេស" ឬ "ផលិតផលចេញពីឈើដាំក្នុងប្រទេស"។

### ១.៣.៣ ផែនការយុទ្ធសាស្រ្ត

យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ឆ្នាំ២០១៩-២០២៣៖ ផ្តោតលើការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ ដើម្បីធានាចីរភាពនៃកំណើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ តាមរយៈការការបង្កើនការដាំ និងស្តារព្រៃឈើឡើងវិញ។

ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ បានបញ្ជាក់ពីភាពចាំបាច់សម្រាប់ប្រទេសកម្ពុជាក្នុងការបង្កើនការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយចីរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំដុះព្រៃឈើឡើងវិញ។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ បានកំណត់សូចនាករគោលដៅជាតិដែលបរិមាណផលឈើដាំត្រូវបានប្រមូលប្រចាំឆ្នាំគឺ២០០.០០០ម៉ែត្រគ្រីគុណ នៅឆ្នាំ២០១៩ និងកើនឡើងបន្តបន្ទាប់ជារៀងរាល់ឆ្នាំរហូតដល់ ៣០០.០០០ម៉ែត្រគ្រីគុណ នៅឆ្នាំ២០២៣។

កម្មវិធីព្រៃឈើជាតិ (២០១០-២០២៩)៖ បានកំណត់យកអាទិភាពលើការងារដាំឈើពហុប្រយោជន៍ ដើម្បីជំរុញការផ្គត់ផ្គង់តម្រូវការក្នុងស្រុក ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពប្រជាជននៅតាមជនបទ ជាពិសេសកាត់បន្ថយសម្ពាធ ប្រើប្រាស់ឈើដែលមានប្រភពពីព្រៃធម្មជាតិ និងសំដៅបង្កើនគម្របព្រៃឈើឡើងវិញ។ សកម្មភាពសំខាន់ៗរួមមាន៖

- ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រតាមរយៈការដាំឈើឡើងវិញ
- ការអភិវឌ្ឍព្រៃឯកជន ដោយផ្តោតសំខាន់លើការដាំឈើជាពហុប្រយោជន៍ ដែលមានសក្តានុពលក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការឈើក្នុងស្រុក និងបង្កើនប្រាក់ចំណូលដល់ប្រជាជនមូលដ្ឋាន
- អភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការលើការបង្កើតចម្ការឈើដាំរវាងសហគមន៍ វិស័យឯកជន និងរដ្ឋបាលព្រៃឈើតាមរយៈការអភិវឌ្ឍ "កិច្ចព្រមព្រៀងគំរូ" ស្តីពីការគ្រប់គ្រង និងការបែងចែកផលប្រយោជន៍

ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ បានពិនិត្យ និងកំណត់នូវគោលដៅនានា ដោយធានាការអភិរក្ស ការស្តារ និងការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ី និងសេវា ជាពិសេសព្រៃឈើតំបន់ភ្នំឱ្យស្របតាមកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអន្តរជាតិ និងបានកំណត់សូចនាករគោលដៅជាតិដោយសម្រេចឱ្យបានគម្របព្រៃឈើ៥០% ត្រឹមឆ្នាំ២០៣០ ដែលត្រូវតែមានការកើនឡើងធៀបទៅនឹង ៤៨,៨% ក្នុងឆ្នាំ២០១៦។

## ១.៤ សិទ្ធិ និងអត្ថប្រយោជន៍នៃព្រៃឯកជន

បុគ្គលដែលបានដាំឈើលើដីឯកជនផ្ទាល់ ឬលើដីព្រៃរបស់រដ្ឋដែលបានប្រគល់សិទ្ធិប្រើប្រាស់ មានសិទ្ធិថែរក្សាអភិវឌ្ឍ ប្រើប្រាស់ លក់ និងចែកចាយផលិតផលរបស់ខ្លួនបាន។ ក្រៅពីនេះ រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនជាកម្មសិទ្ធិករដីធ្លីដែលបានដាំដុះឈើលើដីកម្មសិទ្ធិឯកជន ដើម្បីបង្កើត និងចុះបញ្ជីជាព្រៃឯកជន នឹងទទួលបាននូវការលើកទឹកចិត្តពីរាជរដ្ឋាភិបាលកម្ពុជា នូវអត្ថប្រយោជន៍ជាច្រើនដូចជា ការប្រឹក្សាលើបច្ចេកទេស ការមិនតម្រូវឱ្យបង់បុព្វលាភ ការបញ្ចុះអត្រាអាករនាំចេញលើមុខទំនិញប្រភេទឈើដាំ និងវត្ថុច្នៃពីឈើដាំ ការអនុគ្រោះបន្ថយ ៥០% នៃកាតព្វកិច្ចអាករនាំចេញសរុប លើការនាំចេញមុខទំនិញប្រភេទឈើដាំ និងការដាក់អាករនាំចេញជាបន្ទុករបស់រដ្ឋចំពោះការនាំចេញមុខទំនិញគ្រឿងសង្ហារឹម និងផលិតផលសម្រេចផ្សេងៗទៀត ច្នៃពីឈើដាំក្នុងប្រទេស។

### ១.៤.១ សិទ្ធិនៃកិច្ចដំណើរការដាំឈើ និងការប្រើប្រាស់

ដូចបានកំណត់នៅក្នុងជំពូក៣ នៃប្រកាសលេខ៣២៧ប្រក.កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី "ព្រៃឯកជន" ម្ចាស់ព្រៃឯកជនដែលបានចុះបញ្ជីចម្ការឈើដាំនៅលើ

ដីឯកជនជា "**ព្រៃឯកជន**" មានសិទ្ធិថែរក្សា អភិវឌ្ឍ ប្រើប្រាស់ លក់ និងចែកចាយផលិតផលរបស់ខ្លួនបាន។ ក្នុងករណីម្ចាស់ព្រៃឯកជនត្រូវការជំនួយផ្នែកបច្ចេកទេស រដ្ឋបាលព្រៃឈើអាចផ្តល់នូវសេវាកម្មបណ្តុះបណ្តាលជំនាញបច្ចេកទេសដាំឈើ និងការគ្រប់គ្រងចម្ការព្រៃដាំ។ ការដឹកជញ្ជូនផលិតផលឈើដែលមានប្រភពចេញពីព្រៃឯកជនដើម្បីផ្គត់ផ្គង់ដល់អតិថិជន ឬទីផ្សារក្នុងស្រុក គឺមិនតម្រូវឱ្យមានលិខិតអនុញ្ញាត(LP)ឡើយ។ មុនពេលប្រមូលផលឈើនៅក្នុងចម្ការព្រៃឯកជន ម្ចាស់ព្រៃឯកជនត្រូវជូនដំណឹងដល់រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចនៃមូលដ្ឋានសាមី និងទទួលខុសត្រូវត្រួតពិនិត្យបរិមាណឈើដែលបានប្រមូល និងសកម្មភាពប្រមូលផលរបស់ម្ចាស់ព្រៃឯកជននោះជាលាយលក្ខណ៍អក្សរ។

### *១.៤.២ ប្រតិបត្តិការដោយស្របច្បាប់*

ម្ចាស់ព្រៃឯកជន ត្រូវស្នើសុំសៀវភៅបន្ទុកព្រៃឯកជនរបស់ខ្លួនពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្នុងមូលដ្ឋានសាមី មុនពេលប្រមូលផលឈើដាំ។ ផ្អែកទៅលើប្រកាសស្តីពី "វិធានព្រៃឯកជន" ម្ចាស់ព្រៃឯកជន ត្រូវកត់ត្រារាល់ព័ត៌មានអំពីការប្រមូលផលក្នុងសៀវភៅបន្ទុកព្រៃឯកជនរបស់ខ្លួនដូចជា ទីតាំងឡូត៍ប្រមូលផល ទំហំផ្ទៃដីប្រមូលផល បរិមាណឈើ និងប្រភេទឈើ។ សៀវភៅបន្ទុកនេះគឺមានសារប្រយោជន៍ចំពោះម្ចាស់ព្រៃឯកជន ដើម្បីប្រើជំនួសឱ្យលិខិតអនុញ្ញាតដឹកជញ្ជូននៅពេលដែលត្រូវដឹកជញ្ជូនផលិតផលរបស់ខ្លួនដើម្បីផ្គត់ផ្គង់ដល់អតិថិជនទីផ្សារក្នុងស្រុក ឬនាំចេញ។

ក្នុងករណីម្ចាស់ព្រៃឯកជនមានបំណងចង់បង្កើតសិប្បកម្មកែច្នៃផលិតផលនៅក្នុងទីតាំងព្រៃឯកជន ចាំបាច់ត្រូវធ្វើលិខិតស្នើសុំការអនុញ្ញាតពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្នុងមូលដ្ឋានសាមី។ ក្នុងករណីម្ចាស់ព្រៃឯកជនមានបំណងធ្វើការប្រមូលផលដោយការគាស់ផ្សាំ និងបន្លាស់ទីប្រភេទឈើក្នុងស្រុក ត្រូវជូនដំណឹងរដ្ឋបាលព្រៃឈើមូលដ្ឋានជាលាយលក្ខណ៍អក្សរ ដោយឡែកការដឹកជញ្ជូនទៅកាន់ទីផ្សារត្រូវមានបញ្ជាក់ប្រភពពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច។

## ១.៥ ស្វែងយល់អំពីគោលការណ៍ណែនាំសម្រាប់ចុះបញ្ជីព្រៃឯកជន

### *១.៥.១ តើនរណាដែលត្រូវប្រើគោលការណ៍ណែនាំនេះ?*

- ម្ចាស់ព្រៃឯកជន ឬកម្មសិទ្ធិករព្រៃឯកជន
- មន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗដែលធ្វើការទាក់ទងនឹងការងារដាំឈើជាចម្ការព្រៃឯកជន។

### *១.៥.២ ហេតុអ្វីម្ចាស់ព្រៃឯកជនត្រូវតែប្រើគោលការណ៍ណែនាំនេះ?*

គោលការណ៍ណែនាំនេះ បង្ហាញអំពីដំណើរការបង្កើត និងចុះបញ្ជីព្រៃឯកជន ព្រមទាំងធ្វើការពន្យល់អំពីបទដ្ឋានបច្ចេកទេសដល់ម្ចាស់ព្រៃឯកជនសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍ចម្ការឈើដាំរបស់ខ្លួន។ លើសពីនេះ គោលការណ៍ណែនាំនឹងជួយឱ្យម្ចាស់ព្រៃឯកជន ស្វែងយល់ការលើកទឹកចិត្តដែលមានចែងក្នុងគោលនយោបាយព្រៃឈើ និងក្របខ័ណ្ឌច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព ដោយសារតែការអនុវត្តសកម្មភាពគ្រប់គ្រងព្រៃឈើដែលជួយទៅដល់បរិស្ថាន សង្គម និងប្រសិទ្ធភាពសេដ្ឋកិច្ច។ ម្ចាស់ព្រៃឯកជនអាចស្វែងយល់អំពីដំណើរការបង្កើត និងចុះបញ្ជីព្រៃឯកជនដែលបានពិពណ៌នាក្នុងគោលការណ៍ណែនាំនេះ ការបំពេញបែបបទស្នើសុំចុះបញ្ជី ការរៀបចំផែនការដាំដុះ និងការកត់ត្រាក្នុងសៀវភៅបន្ទុកជាដើម។

លើសពីនេះ គោលការណ៍ណែនាំ ក៏មានពន្យល់អំពីបច្ចេកទេសដាំឈើ ការអនុវត្តរុក្ខវប្បកម្ម និងដំណើរការនៃការប្រមូលផលឈើដាំ ដែលជាផ្នែកមួយដ៏សំខាន់សម្រាប់កម្មសិទ្ធិករព្រៃឯកជន និងភាគីពាក់ព័ន្ធដទៃទៀតសិក្សាស្វែងយល់ និងយកទៅអនុវត្ត។

### *១.៥.៣ តើត្រូវប្រើគោលការណ៍ណែនាំនេះយ៉ាងណា?*

គោលការណ៍ណែនាំ មាន៤ ជំពូក ដូចខាងក្រោម៖

- **ជំពូកទី ១ សេចក្តីផ្តើម៖** ជាជំពូកបង្ហាញអំពីនិយមន័យនៃព្រៃឯកជន គោលបំណង ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ ដែលគាំទ្រដល់ម្ចាស់ព្រៃឯកជន សិទ្ធិក្នុងកិច្ចដំណើរការដាំឈើ និងប្រើប្រាស់កិច្ចដំណើរការអាជីវកម្មដោយស្របច្បាប់។
- **ជំពូកទី ២ គោលការណ៍ណែនាំសម្រាប់ការចុះបញ្ជីព្រៃឯកជន៖** ជាជំពូកសំខាន់នៅក្នុងគោលការណ៍ណែនាំ ដែលមន្ត្រីរដ្ឋបាលព្រៃឈើ រូបវន្តបុគ្គល នីតិបុគ្គល និងអ្នកពាក់ព័ន្ធត្រូវតែស្វែងយល់ និងអនុវត្តការងារបង្កើត និងចុះបញ្ជីព្រៃឯកជនតាមការណែនាំនៅក្នុងជំពូកនេះ។
- **ជំពូកទី ៣ ការរៀបចំផែនការដាំឈើសម្រាប់ចម្ការឈើដាំ និងព្រៃឯកជន៖** ជាជំពូកដែលបង្ហាញអំពីគោលគំនិតសំខាន់ៗពាក់ព័ន្ធនឹងការជ្រើសរើសទីតាំង ការបង្កើតចម្ការឈើដាំ និងការរៀបចំផែនការដាំឈើជាដើម។ ជំពូកនេះ មិនដាក់កំហិតដល់រូបវន្តបុគ្គល នីតិបុគ្គល និងអ្នកពាក់ព័ន្ធ ដែលមានបំណងបង្កើត និងចុះបញ្ជីព្រៃឯកជនត្រូវតែអនុវត្តតាមនោះឡើយ គ្រាន់តែផ្តល់ជាគំនិតមូលដ្ឋានក្នុងការពិចារណា មុននឹងសម្រេចចិត្តដាំឈើតែប៉ុណ្ណោះ។
- **ជំពូកទី ៤ ការប្រមូលផល និងយន្តការនៃការពិនិត្យចម្ការឈើដាំ និងព្រៃឯកជន៖** ជំពូកនេះបង្ហាញអំពីរបៀបនៃការប្រមូលផលឈើពីចម្ការឈើដាំ និងព្រៃឯកជន ការកត់ត្រាទិន្នន័យនៅក្នុងចម្ការឈើរួមមានសកម្មភាពដាំដុះ ប្រភេទឈើ ចំនួនដើម និងបរិមាណឈើដែលបានប្រមូលផលជាដើម ដើម្បីបង្កភាពងាយស្រួលដល់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ក្នុងករណីចាំបាច់។ ជំពូកនេះគឺតម្រូវឱ្យកម្មសិទ្ធិករព្រៃឯកជនចូលរួមសហការជាមួយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដើម្បីធានាបាននូវការគ្រប់គ្រងប្រភពឈើ និងប្រព័ន្ធទិន្នន័យឈើចេញពីចម្ការឈើដាំ និងព្រៃឯកជន។

## ជំពូកទី ២
## គោលការណ៍ណែនាំសម្រាប់ចុះបញ្ជីព្រៃឯកជន

ជំពូកនេះមានបំណងឱ្យមន្ត្រីរដ្ឋបាលព្រៃឈើ រូបវន្តបុគ្គល ឬ នីតិបុគ្គលព្រៃឯកជន និងអ្នកពាក់ព័ន្ធយល់កាន់តែច្បាស់អំពីនីតិវិធីនៃការបង្កើត និងចុះបញ្ជីព្រៃឯកជន។

### ២.១ ចំណាត់ថ្នាក់ និងលក្ខខណ្ឌតម្រូវនៃព្រៃឯកជន

#### *២.១.១ ចំណាត់ថ្នាក់*

យោងតាមប្រកាសលេខ៣២៧ប្រក.កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រៃឯកជនស្នើសុំបង្កើត ត្រូវបានចាត់ថ្នាក់តាមទំហំ ដូចខាងក្រោម៖

- ព្រៃឯកជនលក្ខណៈគ្រួសារ ៖ ផ្ទៃដីទំហំក្រោម១០ហិកតា
- ព្រៃឯកជនទំហំតូច ៖ ផ្ទៃដីទំហំចាប់ពី១០-១០០ហិកតា
- ព្រៃឯកជនទំហំមធ្យម ៖ ផ្ទៃដីទំហំលើសពី១០០-១០០០ហិកតា
- ព្រៃឯកជនទំហំធំ ៖ ផ្ទៃដីទំហំលើសពី ១០០០ហិកតា

#### *២.១.២ លក្ខខណ្ឌតម្រូវ*

លក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំចុះបញ្ជីព្រៃឯកជន រួមមានឯកសារដូចខាងក្រោម៖

- ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន
- ឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី (លិខិតបញ្ជាក់ពីភូមិបាល ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ)
- ប្លង់ទីតាំងដាំដុះឈើបង្កើតជាព្រៃឯកជន
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

#### *២.១.៣ ការប្រឹក្សាមុនដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន*

រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លី ម្ចាស់ចម្ការឈើដាំ ឬដំណុះព្រៃធម្មជាតិ អាចប្រឹក្សាយោបល់ជាមួយមន្ត្រីជំនាញនៃនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជននៃរដ្ឋបាលព្រៃឈើ ឬ មន្ត្រីជំនាញនៃខណ្ឌរដ្ឋបាលព្រៃឈើ មុននឹងស្នើសុំចុះបញ្ជីព្រៃឯកជនរបស់ខ្លួន នូវចំណុចសំខាន់ៗដូចខាងក្រោម៖

- ស្វែងយល់អំពីដំណើរ នៃការបង្កើត និងចុះបញ្ជីព្រៃឯកជន ពាក្យស្នើសុំ និងឯកសារពាក់ព័ន្ធ ព្រមទាំងអត្ថប្រយោជន៍ដែលទទួលបានពីការចុះបញ្ជី
- ប្រឹក្សាយោបល់ជាមួយមន្ត្រី/ផ្នែក ជំនាញ ឬអ្នកពាក់ព័ន្ធ ដើម្បីទទួលបានព័ត៌មានអំពីប្រភេទឈើ និងការវិភាគ តម្រូវការទីផ្សារដែលអាចទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចពីការបង្កើតព្រៃឯកជន
- ពិភាក្សាជាមួយមន្ត្រីជំនាញនៃរដ្ឋបាលព្រៃឈើអំពីទីតាំងដីដែលអាចស្នើសុំចុះបញ្ជីព្រៃឯកជន ការជ្រើសរើស ប្រភេទឈើដែលសមស្របទៅនឹងលក្ខខណ្ឌដី
- ការរៀបចំធ្វើផែនការដាំដុះ ចំពោះព្រៃឯកជនដែលស្នើសុំចុះបញ្ជីលើផ្ទៃដីចាប់ពី ១០(ដប់)ហិកតា

## ២.២ ដំណើរការនៃការស្នើសុំចុះបញ្ជីព្រៃឯកជន

ដំណើរការនៃការស្នើសុំចុះបញ្ជីព្រៃឯកជនមាន ៣ជំហាន ដូចខាងក្រោម ៖

**ជំហានទី១ ការដាក់ពាក្យស្នើសុំ៖** កម្មសិទ្ធិករដីធ្លី បំពេញបែបបទស្នើសុំបង្កើត និងចុះបញ្ជីព្រៃឯកជន ដោយភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ប្លង់ទីតាំងដាំដុះបង្កើតជាព្រៃឯកជន ប្រភេទឈើដាំ និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់

**ជំហានទី២ ការពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃ៖** មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ពិនិត្យលើពាក្យស្នើសុំ និងឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ប្លង់ទីតាំងដាំដុះឈើបង្កើតជាព្រៃឯកជន ប្រភេទឈើដាំ និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់ ចុះពិនិត្យ និងផ្ទៀងផ្ទាត់ទីតាំង និងរាយការណ៍ជូនថ្នាក់ដឹកនាំស្នើសុំការសម្រេច

**ជំហានទី៣ ការចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន៖** ពិនិត្យ និងសម្រេចរបស់ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ម្ចាស់ព្រៃឯកជន ជូនកម្មសិទ្ធិករដីធ្លី។




ដ្យាក្រាម ២.១ ជំហាននៃការស្នើសុំចុះបញ្ជីព្រៃឯកជន

### *២.២.១ ការដាក់ពាក្យស្នើសុំ*

ការដាក់ពាក្យស្នើសុំចុះបញ្ជីជាព្រៃឯកជន អាចធ្វើឡើងនៅរដ្ឋបាលព្រៃឈើថ្នាក់ខេត្ត ឬថ្នាក់កណ្ដាល អាស្រ័យលើប្រភេទព្រៃឯកជន ដែលកម្មសិទ្ធិករដីធ្លីចង់ស្នើសុំឱ្យបង្កើត និងចុះបញ្ជីព្រៃឯកជន។ រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លីតម្រូវឱ្យមាន**ឯកសារភ្ជាប់មកជាមួយពាក្យស្នើសុំដូចជា អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន ឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ប្លង់ទីតាំងដំណុះឈើ បង្កើតជាព្រៃឯកជន ប្រភេទឈើដាំ និង ឯកសារពាក់ព័ន្ធផ្សេងទៀត។** ក្នុងករណីក្រុមហ៊ុនឯកជន ព័ត៌មានដែលតម្រូវការបន្ថែមមានដូចជាវិញ្ញាបនបត្ររបស់ក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬឯកសារដែលមានតម្លៃស្មើ។

**សេចក្តីពន្យល់**

| | | |
|---|---|---|
| អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន(១) | ៖ | ថតចម្លងតាមច្បាប់ដើម (មិនតម្រូវ បញ្ជាក់ពីអាជ្ញាធរមូលដ្ឋានឡើយ) |
| ឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី(២) | ៖ | វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ(លិខិតបញ្ជាក់ពីភូមិបាល) |
| វិញ្ញាបនបត្រចុះបញ្ជីរបស់ក្រុមហ៊ុន(៣) | ៖ | វិញ្ញាបនបត្ររបស់ក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬ ឯកសារដែលមានតម្លៃស្មើ |
| ផែនការដាំដុះបង្កើតព្រៃឯកជន(៤) | ៖ | តម្រូវឱ្យភ្ជាប់មកជាមួយចំពោះការស្នើសុំបង្កើតព្រៃឯកជនលើផ្ទៃដីទំហំលើសពី ១០(ដប់)ហិកតា គំរូផែនការដាំដុះមានពន្យល់ក្នុងជំពូកទី៣ |
| ប្លង់ទីតាំងដំណុះឈើ (៥) | ៖ | ផែនទីបង្ហាញទីតាំងដំណុះឈើត្រូវមានបង្ហាញចំណុចនិយាមកា និង ទីតាំងរដ្ឋបាល (ភូមិ ឃុំ ស្រុក ខេត្ត) |

*សម្គាល់៖ ឯកសារ (១) & (២) ជាឯកសារចាំបាច់ សម្រាប់រូបវន្តបុគ្គល*

*ឯកសារ (១) (២) & (៣) ជាឯកសារចាំបាច់ សម្រាប់នីតិបុគ្គល*

**ការបំពេញពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន**

រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លី ដែលស្នើសុំចុះបញ្ជីព្រៃឯកជនរបស់ខ្លួនអាចប្រើប្រាស់គំរូពាក្យស្នើសុំសម្រាប់ការចុះបញ្ជីព្រៃឯកជន ដូចមានបង្ហាញក្នុងគោលការណ៍ណែនាំនេះ។ រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនអាចស្នើសុំគំរូពាក្យស្នើសុំចុះបញ្ជីព្រៃឯកជនពីនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជននៃរដ្ឋបាលព្រៃឈើ ឬ រដ្ឋបាលព្រៃឈើ រាជធានី ខេត្ត ឬ សរសេរដោយខ្លួនឯង ហើយយ៉ាងណាខ្លឹមសារនៃពាក្យស្នើសុំនេះត្រូវគ្របដណ្តប់រាល់ព័ត៌មានចាំបាច់ និងជូនភ្ជាប់មកជាមួយនូវឯកសារដូចបានបញ្ជាក់ដូចទម្រង់គំរូក្នុងគោលការណ៍ណែនាំនេះ។

## ទម្រង់គំរូពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន

គំរូទី១៖ រូបវន្តបុគ្គល

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

### ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ...................... ភេទ........ អាយុ........ឆ្នាំ មានអាសយដ្ឋានផ្ទះលេខ.......... ផ្លូវ............ភូមិ....................ឃុំ/សង្កាត់...................ស្រុក/ខណ្ឌ...................ខេត្ត/រាជធានី........................

**សូមគោរពជូន**

**លោក/ឯកឧត្តម**............................................................................................

**កម្មវត្ថុ** ៖ សំណើសុំ ចុះបញ្ជីព្រៃឯកជននៅលើផ្ទៃដីទំហំ...........ហិកតា ជាព្រៃឯកជន.............................. ស្ថិតនៅភូមិ...............ឃុំ/សង្កាត់...............ស្រុក/ខណ្ឌ..................ខេត្ត/រាជធានី....................

**ជូនភ្ជាប់** ៖- អត្តសញ្ញាណប័ណ្ណ(ថតចម្លង) ចំនួន ០២ច្បាប់

- ឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ចំនួន ០២ច្បាប់

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទ/នាងខ្ញុំសុំការអនុញ្ញាតពីលោក/ឯកឧត្តម ..............................................ដើម្បីចុះបញ្ជីព្រៃឯកជន......................................... ត្រង់ចំណុចនិយាមកា .......................................ស្ថិតក្នុងភូមិសាស្ត្រភូមិ.................ឃុំ/សង្កាត់...............ស្រុក/ខណ្ឌ.................... ខេត្ត/រាជធានី.................................ដែលមានផ្ទៃដីទំហំ................ហិកតា ឬ ចំនួន....................ដើម។ ប្រភេទឈើដែលត្រូវដាំ ឬបានដាំ

| ល.រ | ឈ្មោះក្នុងស្រុក / ឈ្មោះពាណិជ្ជកម្ម | ចំនួន(ដើម) | ប្រភពពូជ |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| | ........................................................ | | |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក/ឯកឧត្តម......................................មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

ថ្ងៃ............................ខែ............ ឆ្នាំ............... ព.ស...........

........................ ថ្ងៃទី...........ខែ...................ឆ្នាំ២០........

**ហត្ថលេខា ឬ ស្នាមមេដៃ**

ទំនាក់ទំនង៖

ឈ្មោះ.....................................

លេខទូរស័ព្ទ៖...........................

គំរូទី ២៖ នីតិបុគ្គលឯកជន (ក្រុមហ៊ុន ឬវិស័យឯកជន)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..............................ជា..............................ក្រុមហ៊ុន.......................... មានអាសយដ្ឋានផ្ទះលេខ..............ផ្លូវ.................................ភូមិ......................ឃុំ/សង្កាត់................... ស្រុក/ខណ្ឌ............................ខេត្ត/រាជធានី...................................

**សូមគោរពជូន**

**លោក/ឯកឧត្តម**..........................................................................................

**កម្មវត្ថុ** ៖ សំណើសុំចុះបញ្ជីព្រៃឯកជននៅលើផ្ទៃដីទំហំ...............ហិកតា ជាព្រៃឯកជន......................... ស្ថិតនៅភូមិ.................ឃុំ/សង្កាត់..............ស្រុក/ខណ្ឌ............ខេត្ត/រាជធានី.....................

**ជូនភ្ជាប់** ៖- អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន ចំនួន ០២ច្បាប់
- ឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ចំនួន ០២ច្បាប់
- ឯកសារយោង ចំនួន ០២ច្បាប់

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទ/នាងខ្ញុំសុំការអនុញ្ញាតពីលោក/ឯកឧត្តម .............................................ដើម្បីចុះបញ្ជីព្រៃឯកជន.........................................ត្រង់ចំណុចនិយាមកា .....................................ស្ថិតក្នុងភូមិសាស្ត្រភូមិ...................ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ ......................... ខេត្ត/រាជធានី.........................ដែលមានផ្ទៃដីទំហំ...............ហិកតា ឬ ចំនួន.........ដើម។ ប្រភេទឈើដែលត្រូវដាំ ឬបានដាំ

| ល.រ | ឈ្មោះក្នុងស្រុក/ឈ្មោះពាណិជ្ជកម្ម | ចំនួន(ដើម) | ប្រភពពូជ |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| | ............................................... | | |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក/ឯកឧត្តម.....................................មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

ថ្ងៃ............................ខែ............ ឆ្នាំ............. ព.ស.........

..................... ថ្ងៃទី...........ខែ..............ឆ្នាំ២០........

**ហត្ថលេខា ឬ ស្នាមមេដៃ**

ទំនាក់ទំនង៖

ឈ្មោះ៖....................................

លេខទូរស័ព្ទ៖..........................




ដ្យាក្រាម ២.២ ដំណើរការនៃការដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន

ដ្យាក្រាម ២.២ ខាងលើ បង្ហាញអំពីដំណើរការនៃការដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន ដែលអនុវត្តទៅតាមចំណាត់ថ្នាក់ដូចខាងក្រោម៖

- ដំណើរការនៃការដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជនលក្ខណៈគ្រួសារ និងទំហំតូច
  - ពាក្យស្នើសុំដែលបំពេញរួច រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនត្រូវដាក់សុំចុះបញ្ជីព្រៃឯកជននៅខណ្ឌរដ្ឋបាលព្រៃឈើ (ព្រៃឯកជនលក្ខណៈគ្រួសារ) និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី (ព្រៃឯកជនទំហំតូច)
  - មន្ត្រីរដ្ឋបាលដែលទទួលពាក្យស្នើសុំនៅខណ្ឌរដ្ឋបាលព្រៃឈើ ឬ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី ត្រូវពិនិត្យលើសំណុំឯកសារដែល រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានស្នើមក ថាតើព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំ និងឯកសារភ្ជាប់មកជាមួយគ្រប់តាមការណែនាំរបស់គោលការណ៍ណែនាំដែរ ឬទេ?

- ដំណើរការនៃការដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជនទំហំមធ្យម និងទំហំធំ
    - ពាក្យស្នើសុំដែលបំពេញរួច រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនត្រូវដាក់សុំចុះបញ្ជីព្រៃឯកជន នៅរដ្ឋបាលព្រៃឈើ (ព្រៃឯកជនទំហំមធ្យម និងទំហំធំ)
    - មន្ត្រីរដ្ឋបាលដែលទទួលពាក្យស្នើសុំនៅរដ្ឋបាលព្រៃឈើ ត្រូវពិនិត្យលើសំណុំឯកសារដែល រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានស្នើមក ថាតើព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំ និងឯកសារភ្ជាប់ គ្រប់តាមការណែនាំរបស់គោលការណ៍ណែនាំដែរ ឬទេ?
- ករណីឯកសារភ្ជាប់មិនគ្រប់គ្រាន់ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចមានសិទ្ធិមិនបន្តនីតិវិធីនៃការចុះបញ្ជីព្រៃឯកជនជូនរូបវន្តបុគ្គល និង/ឬ នីតិបុគ្គលដែលបានស្នើសុំ។ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ត្រូវរៀបចំលិខិតជូនដំណឹងដល់រូបវន្តបុគ្គល និង\ឬ នីតិបុគ្គលនោះវិញក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃនៃថ្ងៃធ្វើការ។

### *២.២.២ ការពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃ*

ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃទីតាំង ត្រូវអនុវត្តនៅក្នុងជំហានទី២ នៃដំណើរការស្នើសុំបង្កើត និងចុះបញ្ជីព្រៃឯកជន។ បន្ទាប់ពីទទួលបានពាក្យស្នើសុំចុះបញ្ជីព្រៃឯកជនពីរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លី សំណុំឯកសារពាក្យស្នើសុំ និងពិនិត្យ ផ្ទៀងផ្ទាត់ និងផ្តល់មតិដោយមន្ត្រីជំនាញនៃរដ្ឋបាលព្រៃឈើ។ មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចអាចស្នើសុំការអនុញ្ញាតពីប្រធានអង្គភាពរបស់ខ្លួន ដើម្បីចុះត្រួតពិនិត្យ ប្រមូលព័ត៌មាន និងវាយតម្លៃស្ថានភាពនៃទីតាំងចម្ការឈើដែលបានស្នើសុំចុះបញ្ជីព្រៃឯកជន។




ដ្យាក្រាម ២.៣ លំហូរនៃការពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃព្រៃឯកជនលក្ខណៈគ្រួសារ និងព្រៃឯកជនទំហំតូច

តាមដ្យាក្រាម ២.៣ ខាងលើ បង្ហាញអំពីដំណើរការពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃព្រៃឯកជនលក្ខណៈគ្រួសារ និងព្រៃឯកជនទំហំតូច។ បន្ទាប់ពីទទួលពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី នឹងបញ្ជូនសំណុំឯកសារនេះមកខណ្ឌរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចពិនិត្យ និងចុះផ្ទៀងផ្ទាត់នៅទីវាល។

មន្ត្រីចុះពិនិត្យ និងផ្ទៀងផ្ទាត់នៅទីវាល ត្រូវធ្វើការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងកម្មសិទ្ធិករព្រៃឯកជន ព្រមទាំងរៀបចំកំណត់ហេតុ "លទ្ធផលស្តីពីការងារចុះពិនិត្យ និងផ្ទៀងផ្ទាត់នៅទីវាល" រួចរាយការណ៍ជា

លាយលក្ខណ៍អក្សរមកមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ដើម្បីពិនិត្យសម្រេច និងស្នើសុំវិញ្ញាបនបត្រ បញ្ជាក់ម្ចាស់ព្រៃឯកជនពីរដ្ឋបាលព្រៃឈើ។

ករណីទីតាំងស្នើសុំចុះបញ្ជីពុំទាន់បានបំពេញគ្រប់លក្ខខណ្ឌខាងលើ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវរៀបចំលិខិតជូនដំណឹងដល់រូបវន្ត ឬនីតិបុគ្គលឯកជនវិញ ព្រមទាំងណែនាំឱ្យធ្វើការបំពេញបន្ថែម និងស្នើសុំសារជាថ្មីឡើងវិញ ។




ដ្យាក្រាម ២.៤ លំហូរនៃការពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃព្រៃឯកជនទំហំមធ្យម និងព្រៃឯកជនទំហំធំ

តាមដ្យាក្រាម ២.៤ ខាងលើ បង្ហាញអំពីដំណើរការ ពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃព្រៃឯកជនទំហំមធ្យម និងព្រៃឯកជនទំហំធំ។ បន្ទាប់ពីទទួលពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន៖

- ***<u>ព្រៃឯកជនទំហំមធ្យម</u>*៖** រដ្ឋបាលព្រៃឈើ ត្រូវចាត់មន្ត្រីជំនាញពិនិត្យលើសំណុំឯកសារដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានស្នើមក។ ករណីនេះ ឯកសារស្នើសុំបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់គោលការណ៍ណែនាំ រដ្ឋបាលព្រៃឈើនឹងចាត់មន្ត្រីជំនាញដើម្បីចុះពិនិត្យ និងផ្ទៀងផ្ទាត់នៅទីវាល។
- ***<u>ព្រៃឯកជនទំហំធំ</u>*៖** រដ្ឋបាលព្រៃឈើ ត្រូវចាត់មន្ត្រីជំនាញ ដើម្បីចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃរួចរាយការណ៍ និងស្នើសុំគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

***<u>ចំណាំ</u>*៖** ករណីទីតាំងស្នើសុំចុះបញ្ជីពុំទាន់បានបំពេញគ្រប់លក្ខខណ្ឌខាងលើ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវរៀបចំលិខិតជូនដំណឹងដល់រូបវន្ត ឬនីតិបុគ្គលឯកជនវិញ ព្រមទាំងណែនាំឱ្យធ្វើការបំពេញបន្ថែម និងស្នើសុំសារជាថ្មីឡើងវិញ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃនៅទីវាល ដោយមានការចូលរួមសហការជាមួយអ្នកពាក់ព័ន្ធ ព្រមទាំងរៀបចំកំណត់ហេតុ "លទ្ធផលស្តីពីការងារចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃនៅទីវាល" ជាមួយកម្មសិទ្ធិករព្រៃឯកជន រួចរាយការណ៍ពីលទ្ធផលមករដ្ឋបាលព្រៃឈើ ដើម្បីពិនិត្យ និងសម្រេច។

# គំរូទម្រង់ព័ត៌មានចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃ

## សាលាកបត្រព័ត៌មានចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃ

**ផ្នែក កៈ អត្តសញ្ញាណម្ចាស់ចម្ការឈើ**

១-ឈ្មោះអ្នកស្នើសុំ ៖ ..............................................................

២-ថ្ងៃខែឆ្នាំកំណើត ៖ .................................... សញ្ជាតិ ...................

៣-អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនលេខ៖ ..........................................................

ចុះថ្ងៃទី......... ខែ................ ឆ្នាំ................

៤-មុខរបរ ៖ ..............................................................

៥-ចម្ការឈើដាំ ៖ ☐ គ្រួសារ ☐ឯកជន ☐ក្រុមហ៊ុនឬនីតិបុគ្គល

៦-អាសយដ្ឋានអចិន្ត្រៃយ៍ ៖..............................................................

..........................................................................................................

ទូរស័ព្ទ/ទូរសារ ........................................................ អ៊ីម៉ែល ...........................................

គេហទំព័រ........................................................................................................

៧-ប្រភេទព្រៃឯកជន ៖

☐ លក្ខណៈគ្រួសារ ☐ ទំហំតូច ☐ ទំហំមធ្យម ☐ ទំហំធំ

៨-ទំហំព្រៃឯកជនសរុប ឬ ចំនួនដើម៖ ..........................ហិកតា ឬ ចំនួន ................ដើម

៩-ទីតាំងព្រៃឯកជន(ភ្ជាប់ជាមួយប្លង់ ឬផែនទីសម្គាល់ )

..........................................................................................................

..........................................................................................................

**ផ្នែក ខៈ ព័ត៌មានបញ្ជាក់កម្មសិទ្ធិដីធ្លី**

១០-ប្រភេទដីឯកជន ៖ ☐ ដីឯកជន (ផ្ទាល់ខ្លួន) ☐ ដីកិច្ចសន្យាជួល (រយៈពេលវែង ឬខ្លី)

☐ ដីសម្បទានសេដ្ឋកិច្ច ☐ ផ្សេងៗ.........................................

១១-ករណីដីឯកជន(ផ្ទាល់ខ្លួន) ប្រភេទសម្គាល់កម្មសិទ្ធិអចលនវត្ថុ

☐ បង្កាន់ដៃទទួលពាក្យ (ឆ្នាំ១៩៩០) ☐ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (រដ្ឋកម្ពុជា)

☐ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី (១៩៩១) ☐ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ (ប័ណ្ណស)

☐ ផ្សេងៗ............................................................................

១២-ករណីដីកិច្ចសន្យាជួល៖ វិញ្ញាបនបត្រសម្គាល់សិទ្ធិ...............

☐ ជួលអចិន្ត្រៃយ៍នៃចំណែកឯកជន ☐ សម្បទានដីសេដ្ឋកិច្ច ☐ ជួលរយៈពេលវែង

☐ ផ្សេងៗ..........................................................................

១៣- តើប្រភេទដីនេះត្រូវបានជួលក្នុងរយៈពេលប៉ុន្មានឆ្នាំ?..............................................

តើមានកិច្ចសន្យាជួលដែរ ឬទេ?☐ មាន (ករណីមានសូមភ្ជាប់ កិច្ចសន្យា) ☐ មិនមាន

**ផ្នែក គៈ ពិពណ៌នាអំពីចម្ការឈើដាំ ឬ ដំណុះព្រៃធម្មជាតិ**

**១៤- គោលបំណងនៃការបង្កើតព្រៃឯកជនៈ**

☐ បង្កើតជាចម្ការឈើដាំដុះប្រភេទឈើដែលមានដោយកម្រសម្រាប់ធ្វើពាណិជ្ជកម្មនាំចេញ

☐ បង្កើតជាចម្ការឈើឯកជនសម្រាប់ប្រមូលផលលក់ ផ្គត់ផ្គង់តម្រូវការទីផ្សារ

☐ បង្កើតជាចម្ការឈើឯកជន ដោយដាំដុះឈើចម្រុះប្រភេទសម្រាប់អភិរក្សពូជ និងអភិវឌ្ឍន៍អេកូទេសចរណ៍

☐ ផ្សេងៗៈ...............................................................................................

១៥-បញ្ជីឈ្មោះឈើ ដែលត្រូវដាំ ឬបានដាំៈ

| ល.រ | ប្រភេទ | ចំនួន (ដើម) | ទំហំផ្ទៃដី (ហ.ត) | ឆ្នាំដាំដុះ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| | ........................................................ | | | |

១៦-តើអ្នកមានផែនទីបង្ហាញឡូត៍ដាំដុះទេ? ☐ មាន (ករណីមានសូមបង្ហាញ) ☐ គ្មាន

មូលវិចារ ឬ ការផ្តល់មតិៈ

.....................................................................................................................................................................

.....................................................................................................................................................................

.....................................................................................................................................................................

.....................................................................................................................................................................

.....................................................................................................................................................................

ថ្ងៃ...........................ខែ.............ឆ្នាំ.................ព.ស. ..........

................. ថ្ងៃទី.................ខែ..........ឆ្នាំ២០......

សមាសភាពអ្នកចូលរួមចុះពិនិត្យ និងវាយតម្លៃៈ

| ឈ្មោះ | មុខងារ | អង្គភាព | ហត្ថលេខា |
|---|---|---|---|
| ...................................................................................................... | | | ............................................... |
| ...................................................................................................... | | | ............................................... |
| ...................................................................................................... | | | ............................................... |
| ...................................................................................................... | | | ............................................... |
| ...................................................................................................... | | | ............................................... |

***សម្គាល់***ៈ ការចុះមូលវិចារអាចបរិយាយពីសកម្មភាពជាក់ស្តែងពាក់ព័ន្ធនឹងទីតាំងចម្ការឈើដាំ ឬ ដំណុះព្រៃធម្មជាតិ ដូចជាស្ថានភាពនៃការកាន់កាប់ ការតវ៉ា បញ្ហាទំនាស់ដីធ្លីជាដើម ជាពិសេសរៀបរាប់ដោយសង្ខេបអំពីស្ថានភាពវិវត្តន៍ចម្ការឈើដាំ។

### ២.២.៣ ការផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន

រដ្ឋបាលព្រៃឈើនឹងផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន តាមសំណើរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត (ព្រៃឯកជនលក្ខណៈគ្រួសារ និងព្រៃឯកជនទំហំតូច) និងតាមសំណើរបស់អង្គភាពជំនាញក្រោមឱវាទរដ្ឋបាលព្រៃឈើ (ព្រៃឯកជនទំហំមធ្យម និងទំហំធំ[1]) ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ និងកំណត់ហេតុចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃនៅទីវាល។

វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជននេះ នឹងផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជនក្នុងរយៈពេលមិនលើសពី ៤៥ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលពាក្យ ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ឯកសារបញ្ជាក់កម្មសិទ្ធិដីធ្លីស្របតាមច្បាប់ភូមិបាល (ថតចម្លងតាមច្បាប់ដើម)
- ទីតាំងដីស្នើសុំមានសុវត្ថិភាព
- ករណីដីដាំឈើត្រូវបានជួលពីឯកជនក្នុងរយៈពេលវែង ដោយមានកិច្ចសន្យាជួល និងការឯកភាពពីម្ចាស់អចលនវត្ថុក្នុងការចុះបញ្ជីជាព្រៃឯកជនដោយលាយលក្ខណ៍អក្សរ
- ប្រភេទឈើដែលបានដាំ យ៉ាងហោចណាស់បង្កើតជាគម្របដីលើសពី ៣៥ភាគរយ។

ដោយឡែក ករណីទីតាំងស្នើសុំចុះបញ្ជីពុំទាន់បានបំពេញគ្រប់លក្ខខណ្ឌខាងលើ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវរៀបចំលិខិតជូនដំណឹងដល់រូបវន្ត ឬនីតិបុគ្គលឯកជនវិញ ព្រមទាំងណែនាំឱ្យធ្វើការបំពេញបន្ថែម និងស្នើសុំសារជាថ្មីឡើងវិញ ។

ការចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន អាចចេញជូនម្ចាស់កម្មសិទ្ធិដីឯកជនជាទំហំផ្ទៃដី និង/ឬជាចំនួនដើមឈើក៏បាន ដែលមានតម្លៃស្មើគ្នា ដោយអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងដែលម្ចាស់បានដាំដើមឈើក្រោមរូបភាពជាចម្ការឈើ ឬ ការដាំដើមឈើជារបងតាមព្រំដីជាដើម។ គំរូវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជនត្រូវបានកំណត់ដោយរដ្ឋបាលព្រៃឈើដែលមានទម្រង់ដូចខាងក្រោម៖

[1] ព្រៃឯកជនទំហំធំ៖ រដ្ឋបាលព្រៃឈើអាចចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជនបាន លុះត្រាមានគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

# គំរូវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន (ផ្នែកខាងមុខ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋបាលព្រៃឈើ

លេខ....................រព/នពជ

## វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន

### ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញប្រកាសលេខ៣២៧ប្រក.កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ ស្តីពីវិធានព្រៃឯកជន
- បានឃើញពាក្យស្នើសុំរបស់ឈ្មោះ..................................................ចុះថ្ងៃទី..........ខែ.........................ឆ្នាំ២០............
- យោងលិខិតលេខ...............ចុះថ្ងៃទី.......ខែ.........ឆ្នាំ២០.............របស់.....................................................................

### បញ្ជាក់ថា

ឈ្មោះ៖...........................................................ភេទ...........................................................................

មុខរបរ៖ .........................................................................................................................................

អាសយដ្ឋាន៖ ....................................................................................................................................

.......................................................................................................................................................

បានដាំឈើនៅចំណុចនិយាមកា...................................................ស្ថិតនៅភូមិ........................ឃុំ/សង្កាត់
...................................ស្រុក/ខណ្ឌ............................ខេត្ត/រាជធានី...............................

**ត្រូវបានចុះបញ្ជីជាព្រៃឯកជន**..................................។

វិញ្ញាបនបត្រនេះត្រូវបានប្រគល់ជូនកម្មសិទ្ធិករឯកជន រួមជាមួយសៀវភៅបន្ទុកព្រៃឯកជន ដើម្បីប្រើប្រាស់ និងទទួលខុសត្រូវអនុវត្ត ដោយអនុលោមតាមប្រកាសស្តីពីវិធានព្រៃឯកជន។

ថ្ងៃ...........................ខែ........... ឆ្នាំ.......................ព.ស.២៥៦....

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ..........ឆ្នាំ២០........

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលព្រៃឈើ**

សម្គាល់៖ វិញ្ញាបនបត្រនេះទទួលស្គាល់តែលើដើមឈើដែលដាំប៉ុណ្ណោះ។

## គំរូវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន (ផ្នែកខាងក្រោយ)

ឈ្មោះកម្មសិទ្ធិករព្រៃឯកជន៖ លេខ៖....................រព/នពជ

**បញ្ជីកត់ត្រាឈ្មោះឈើ ចំនួន (ដើម) និងផ្ទៃដីដាំដុះ (ហិកតា)**

| ល.រ | ប្រភេទឈើ | ឈ្មោះវិទ្យាសាស្ត្រ | ផ្ទៃដី (ហិកតា) | ចំនួន (ដើម) | កាលបរិច្ឆេទដាំដុះ | កំណត់សម្គាល់ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## គំនូសបំព្រួញសង្ខេបអំពីដំណើរការស្នើសុំចុះបញ្ជីព្រៃឯកជន




ដ្យាក្រាម ២.៥ ដំណើរការស្នើសុំចុះបញ្ជីព្រៃឯកជន

តារាង២.១ ដំណើរការនៃការដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជនលក្ខណៈគ្រួសារ និងទំហំតូច

| ជំហាន | ដំណើរការ |
|---|---|
| ***ជំហានទី១៖*** *ការដាក់ពាក្យស្នើសុំចុះបញ្ជី* | o ពាក្យស្នើសុំដែលបំពេញរួច រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជន ត្រូវដាក់សុំចុះបញ្ជីព្រៃឯកជននៅខណ្ឌរដ្ឋបាលព្រៃឈើ (ព្រៃឯកជនលក្ខណៈគ្រួសារ) និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី (ព្រៃឯកជនទំហំតូច)<br>o មន្ត្រីរដ្ឋបាលដែលទទួលពាក្យស្នើសុំនៅខណ្ឌរដ្ឋបាលព្រៃឈើ ឬ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ត្រូវពិនិត្យលើសំណុំឯកសារដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានស្នើមក ថាតើព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំ និងឯកសារភ្ជាប់មកជាមួយគ្រប់គ្រាន់តាមការណែនាំរបស់គោលការណ៍ណែនាំដែរ ឬទេ? |
| ***ជំហានទី២៖ ការពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃ*** | o មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី ត្រូវស្នើបញ្ជូនសំណុំឯកសារនេះឱ្យមកខណ្ឌរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចធ្វើការពិនិត្យលើសំណុំឯកសារដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានស្នើមក។ ករណីនេះ ខណ្ឌ រដ្ឋបាលព្រៃឈើ អាចនឹងស្នើសុំការអនុញ្ញាតពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី ដើម្បី |

| ជំហាន | ដំណើរការ |
|---|---|
| | ចុះពិនិត្យ និងផ្ទៀងផ្ទាត់នៅទីវាល ប្រសិន បើពិនិត្យឃើញថាឯកសារបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់គោលការណ៍ណែនាំនេះ។<br>○ មន្ត្រីចុះបេសកកម្មត្រួតពិនិត្យ និងផ្ទៀងផ្ទាត់នៅទីវាល ត្រូវធ្វើការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំង រៀបចំកំណត់ហេតុ "លទ្ធផលស្តីពីការងារចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់នៅទីវាល" ជាមួយកម្មសិទ្ធិករព្រៃឯកជន បន្ទាប់មករាយការណ៍ជាលាយលក្ខណ៍អក្សរមកមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត ដើម្បីសុំការពិនិត្យ និងសម្រេច។ |
| ***ជំហានទី៣៖ ការចេញវិញ្ញាបនបត្រ*** *(Certification)* | រដ្ឋបាលព្រៃឈើនឹងផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន ជូនរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន តាមសំណើរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត (ព្រៃឯកជនលក្ខណៈគ្រួសារ និង ព្រៃឯកជនទំហំតូច) ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ និងកំណត់ហេតុចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃនៅទីវាល។<br>ករណីទីតាំងស្នើសុំចុះបញ្ជីពុំទាន់បានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវរៀបចំលិខិតជូនដំណឹងដល់រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនវិញ ព្រមទាំងណែនាំឱ្យធ្វើការបំពេញបន្ថែម និងស្នើសុំសារជាថ្មីឡើងវិញ ។ |

តារាង២.២ ដំណើរការនៃការដាក់ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជនទំហំមធ្យម និងទំហំធំ

| ជំហាន | ដំណើរការ |
|---|---|
| ***ជំហានទី១៖*** *ការដាក់ពាក្យស្នើសុំបង្កើត* | ○ ពាក្យស្នើសុំដែលបំពេញរួចរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនត្រូវដាក់សុំចុះបញ្ជីព្រៃឯកជននៅរដ្ឋបាលព្រៃឈើ (សម្រាប់ព្រៃឯកជនទំហំមធ្យម និងព្រៃឯកជន ទំហំធំ)<br>○ មន្ត្រីរដ្ឋបាលដែលទទួលពាក្យស្នើសុំនៅរដ្ឋបាលព្រៃឈើ ត្រូវពិនិត្យលើសំណុំឯកសារដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនបានស្នើមក ថាតើព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំ និងឯកសារភ្ជាប់មកជាមួយ គ្រប់តាមការណែនាំរបស់គោលការណ៍ណែនាំដែរ ឬទេ? |
| ***ជំហានទី២៖ ការពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃ*** | ○ ***<u>ព្រៃឯកជនទំហំមធ្យម</u>***៖ រដ្ឋបាលព្រៃឈើ ត្រូវចាត់មន្ត្រីជំនាញពិនិត្យលើសំណុំឯកសារដែលរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនបានស្នើមក។ ករណីនេះ ឃើញថាឯកសារស្នើសុំបានបំពេញតាមលក្ខខណ្ឌ តម្រូវរបស់គោលការណ៍ណែនាំ រដ្ឋបាលព្រៃឈើនឹងចាត់មន្ត្រីនៃអង្គភាពជំនាញក្រោមឱវាទ ដើម្បីចុះពិនិត្យ និងផ្ទៀងផ្ទាត់នៅទីវាល ។<br>○ ***<u>ព្រៃឯកជនទំហំធំ</u>***៖ រដ្ឋបាលព្រៃឈើ ត្រូវចាត់មន្ត្រីនៃអង្គភាពជំនាញក្រោមឱវាទ ដើម្បីចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃ ប្រសិនបើពិនិត្យឃើញថា ឯកសារបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់គោលការណ៍ណែនាំ រួចរាយការណ៍ និងស្នើសុំគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។<br>○ មន្ត្រីចុះបេសកកម្មត្រួតពិនិត្យ និងផ្ទៀងផ្ទាត់នៅទីវាល ត្រូវធ្វើការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងកម្មសិទ្ធិករព្រៃឯកជន ព្រមទាំងរៀបចំកំណត់ហេតុ "លទ្ធផលស្តីពី |

| ជំហាន | ដំណើរការ |
| --- | --- |
| | ការងារចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់នៅទីវាល រួចរាយការណ៍ជាលាយលក្ខណ៍ អក្សរមករដ្ឋបាលព្រៃឈើ ដើម្បីសុំការពិនិត្យ និងសម្រេច។ |
| ***ជំហានទី៣៖ ការចេញវិញ្ញាបនបត្រ (Certification)*** | រដ្ឋបាលព្រៃឈើនឹងផ្តល់វិញ្ញា បនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន ជូនរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានដាក់ពាក្យ ស្នើចុះបញ្ជីព្រៃឯកជន តាមសំណើរបស់អង្គភាពជំនាញក្រោមឱវាទរដ្ឋបាលព្រៃឈើ (ព្រៃឯកជនទំហំមធ្យម) និងមានគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ព្រៃឯកជនទំហំធំ) ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ និងកំណត់ហេតុចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃនៅទីវាល។<br>ករណីទីតាំងស្នើសុំចុះបញ្ជីពុំទាន់បានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវរៀបចំលិខិតជូនដំណឹងដល់រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនវិញ ព្រមទាំងណែនាំឱ្យធ្វើការបំពេញបន្ថែម និងស្នើសុំសារជាថ្មីឡើងវិញ ។ |

# ជំពូកទី ៣
# ការរៀបចំផែនការដាំឈើសម្រាប់ចម្ការឈើដាំ និងព្រៃឯកជន

## ៣.១ ការវាយតម្លៃទីតាំងដាំឈើ

ការជ្រើសរើសទីតាំងដីសម្រាប់គម្រោងដាំឈើ ជាចំណុចសំខាន់ ដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលគួរសិក្សាឱ្យបានច្បាស់លាស់ មុនពេលសម្រេចចិត្តទិញ ឬការបណ្តាក់ទុនរួមគ្នាក្នុងការបង្កើតជាចម្ការឈើដាំ និងព្រៃឯកជន ដែលចំណុចគួរពិចារណាពីកត្តាបរិស្ថាន សេដ្ឋកិច្ច និងសង្គម។ ប្រសិនបើព្រៃឯកជនត្រូវបានបង្កើតឡើងសម្រាប់ចម្ការឈើពាណិជ្ជកម្ម ដូច្នេះយើងអាចបង្កើតនៅកន្លែងដែលមានលក្ខខណ្ឌដី និងអាកាសធាតុ (បរិមាណ និងរបាយទឹកភ្លៀង) សមស្របសម្រាប់ការដុះលូតលាស់នៃប្រភេទឈើ ។ ដោយឡែក ទីតាំងផ្សេងទៀតដែលជាចម្ការឈើមិនមែនជាទិសដៅសម្រាប់ការធ្វើពាណិជ្ជកម្ម នោះអាចបង្កើតជាព្រៃឯកជនដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៍បរិស្ថាន និងសង្គម។

ការវាយតម្លៃទីតាំងគួរចាប់ផ្តើមនៅដំណាក់កាលដំបូងមុនការរៀបចំដី ដោយពិនិត្យលើ៖

- ស្ថានភាពដី សារព័ន្ធរុក្ខជាតិ និងសត្វព្រៃ ដោយប្រើប្រាស់មធ្យោបាយវាយតម្លៃដោយឆាប់រហ័ស
- ស្ថានភាពនៃការប្រើប្រាស់ដី ស្របតាមប្រព័ន្ធកំណត់នៃសិទ្ធិកាន់កាប់ដីធ្លី មិនពាក់ព័ន្ធនឹងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ឬ ដែនព្រៃនៃតំបន់ការពារធម្មជាតិ
- វិភាគសេដ្ឋកិច្ចលើកម្លាំងពលកម្មការងារ
- ឥទ្ធិពលពីផលប៉ះពាល់នានាដែលអាចកើតមានដូចជា ការហូរច្រោះ ការបំពុលទឹក ការខ្វះខាតទឹក និង/ឬ គ្មានប្រភពទឹក ព្រមទាំងកត្តាផ្សេងៗទៀត។

### *៣.១.១ គោលការណ៍*

ការបង្កើតចម្ការឈើ និងព្រៃឯកជន គឺជាការចូលរួមចំណែករបស់ម្ចាស់ព្រៃឯកជនទាំងរូបវន្តបុគ្គល និងនីតិបុគ្គលក្នុងកិច្ចខិតខំប្រឹងប្រែងជំរុញខឿនសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើតប្រភពនៃការផ្គត់ផ្គង់ឈើចេញពីចម្ការឈើដាំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលឈើចេញពីព្រៃធម្មជាតិ ជាពិសេសបង្កើតការងារជួយបង្កើនប្រាក់ចំណូលដល់សហគមន៍មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រតាមតំបន់ជនបទជាដើម។

ការរៀបចំផែនការដាំឈើ រូបវន្តបុគ្គល និងនីតិបុគ្គលអាចគិតគូរនូវតម្លៃមួយចំនួនដូចជាការលំហែកម្សាន្ត គុណភាពនៃតំបន់ទេសភាព ភូមិសាស្ត្រ ជីវសាស្ត្រ និងបេតិកភណ្ឌវប្បធម៌។

### *៣.១.២ ការវិភាគចំណាយ*

ការបង្កើតចម្ការឈើដាំ ឬ ព្រៃឯកជន ទោះបីជាមានទំហំតូចក្តីត្រូវចំណាយខ្ពស់ណាស់។ ការចំណាយលើការទិញដី ការទិញឧបករណ៍ និងសម្ភារសម្រាប់ដាំឈើ ការជួលដី ការជួលកម្មករ ការកសាងផ្លូវ ការធ្វើរបង ការថែរក្សាការពារ និងការដឹកជញ្ជូនជាដើម។ ប្រសិនបើម្ចាស់ព្រៃឯកជន បានធ្វើផែនការច្បាស់លាស់នោះ សោហ៊ុយចំណាយនឹងត្រូវកាត់បន្ថយ។ ក្នុងន័យនេះត្រូវសួរខ្លួនឯងថា៖

- តើការបង្កើត ព្រៃឯកជនក្នុងគោលបំណងអ្វី? (តម្លៃទេសភាព លំហែកម្សាន្ត ឬ ធ្វើពាណិជ្ជកម្ម)
- តើការរៀបចំដីធ្វើឡើងដោយកម្លាំងពលកម្ម ឬ ដោយគ្រឿងចក្រ?
- តើត្រូវការរបងប៉ុន្មាន? តើប្រើសម្ភារសំណង់អ្វី ហើយថ្លៃប៉ុន្មាន? ។ល។

### *៣.១.២ ការវិភាគសេដ្ឋកិច្ច*

ឆ្លងកាត់ដំណើរការសិក្សាទីតាំងរួច ប្រសិនបើម្ចាស់ព្រៃឯកជនសម្រេចចិត្តធ្វើការដាំឈើ ដូច្នេះកិច្ចការបន្ទាប់គឺការរៀបចំផែនការដាំដុះ។ ការរៀបចំផែនការបង្កើតចម្ការឈើឯកជនសម្រាប់ធ្វើពាណិជ្ជកម្ម គួរមានព័ត៌មានស្តីពីការវិភាគប្រសិទ្ធិភាពសេដ្ឋកិច្ច ដើម្បីបង្ហាញថាគម្រោងដាំឈើនេះនឹងមានផលចំណេញសម្រាប់ជាមូលដ្ឋានក្នុងការសម្រេចចិត្តវិនិយោគ។

ចំណុចសំខាន់ៗដែលត្រូវវិភាគមានដូចជា៖

- ផ្តោតលើការប៉ាន់ស្មានជាក់ស្តែងនៃតំបន់ដែលត្រូវដាំ ដោយមិនរាប់បញ្ចូលតម្លៃបរិស្ថាន និងធ្វើការប៉ាន់ស្មានជាក់ស្តែងនៃចំណូលហិរញ្ញវត្ថុ និងការបង្កើត ការថែរក្សា និងការចំណាយលើការការពារជាដើម
- គិតគូរពីផលប៉ះពាល់នៃសណ្ឋានដី និងលទ្ធភាពទទួលបានពីថ្លៃដើមនៃការប្រមូលផល និងការដឹកជញ្ជូន
- ប្រើប្រាស់ទិន្នន័យពីការលូតលាស់ចម្ការឈើក្នុងតំបន់ដែលមានលក្ខខណ្ឌស្រដៀងគ្នា សម្រាប់ការប៉ាន់ស្មានអំពីផលិតភាព និងទិន្នផល
- ពិចារណាលើហានិភ័យដែលអាចកើតមានពីជំងឺ អគ្គិភ័យ សត្វល្អិត និងគ្រោះមហន្តរាយធម្មជាតិផ្សេងទៀត។

## ៣.២ ការរៀបចំចម្ការឈើដាំ

កត្តាដែលគួរត្រូវបានយកមកពិចារណាក្នុងការរៀបចំចម្ការឈើដាំរួមមាន៖

- សារព័ន្ធរុក្ខជាតិដែលមានស្រាប់ ថាតើនៅតែមានសក្តានុពលក្នុងការស្តារដំណុះព្រៃឡើងវិញ និងអាចប្រើប្រាស់បានដែរ ឬទេ?
- ការធ្វើផ្លូវដឹកជញ្ជូន និងផ្លូវភ្លើង សម្រាប់ចម្ការព្រៃឯកជនដែលមានទំហំលើសពី ១០ហិកតា ត្រូវមានវិធានការ ការពារ និងគ្រប់គ្រងភ្លើងព្រៃ
- វិធានការការពារទប់ទល់នឹងជំងឺ និងសត្វល្អិតបំផ្លាញ
- ផែនការទីផ្សារ និងការប្រើប្រាស់ឈើ
- ការកាន់កាប់ដី ត្រូវកំណត់នូវភាពស្របច្បាប់នៃទីតាំងដែលត្រូវដាំឈើ ត្រូវមើលផងដែរថាតើនៅមានចម្លោះអំពីការកាន់កាប់ដីដែលមិនទាន់បានដោះស្រាយដែរឬទេ មុននឹងចាប់ផ្តើមដាំឈើ?
- ទំហំចម្ការឈើ មិនមានគោលការណ៍កំណត់ច្បាស់លាស់អំពីទំហំចម្ការដាំឈើទេ។ ជាទូទៅចម្ការឈើកាន់តែធំ នោះការចំណាយក្នុងមួយឯកត្តាដីមានទំហំតូចជាង ដូច្នេះការផ្លាស់ប្តូរដី ឬក៏ការចូលហ៊ុនគ្នាក្នុងការធ្វើវិនិយោគអាចចាត់ទុកថាធ្វើឱ្យការចំណាយក្នុងការបង្កើតចម្ការឈើដាំមានកម្រិតទាប។
- កម្លាំងពលកម្ម ការងារដាំឈើ ភាគច្រើនត្រូវអនុវត្តដោយកសិករនៅក្នុងកំឡុងពេលក្រៅពីរដូវដាំដុះ។ ប្រសិនបើចម្ការឈើមានទំហំធំពេកដែលពិបាកគ្រប់គ្រងនោះ គេត្រូវជួលកម្មករបន្ថែមពីក្រៅ។ បញ្ហានេះ គេច្រើនជួបប្រទះនៅពេលរៀបចំចម្ការ និងពេលដាំដុះ។ ការជួលកម្លាំងពលកម្មពីក្រៅត្រូវផ្តល់ទីកន្លែង សម្រាប់ស្នាក់នៅផងដែរ។

## ៣.៣ ការជ្រើសរើសទីតាំងសម្រាប់ដាំឈើ

### *៣.៣.១ ភាពដែលអាចចូលដល់*

ដើម្បីកាត់បន្ថយសោហ៊ុយចំណាយលើការសាងសង់ផ្លូវ គេត្រូវជ្រើសរើសទីតាំងណាដែលទាមទារការកសាងផ្លូវតិចបំផុត។ ការដឹកជញ្ជូនក៏មានតម្លៃថ្លៃផងដែរ ដូច្នេះចម្ការដាំឈើគួរតែ:

- ស្ថិតនៅជិតផ្លូវមេ និងផ្លូវបន្ទាប់
- នៅជិតប្រភពផ្គត់ផ្គង់ និងតម្រូវការ
- នៅជិតភូមិ ឬនៅជិតទីផ្សារលក់ផលិតផលឈើ

### ៣.៣.២ សណ្ឋានដី

សណ្ឋានដីសំដៅទៅលើ ជម្រាលនៃទីតាំង ភាពមានដុំថ្ម ឬផ្ទាំងថ្ម រយៈកម្ពស់ និងការប្រឈមទៅនឹងពន្លឺព្រះអាទិត្យ។ ជម្រាលគឺជាធាតុសំខាន់មួយដែលត្រូវពិចារណា។ ទីតាំងដែលមានជម្រាលខ្លាំងតែងតែមានដីស្រទាប់លើរាក់ ហើយងាយរងការហូរច្រោះ។ នៅក្នុងទីតាំងទាំងឡាយណាដែលមានកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំច្រើនជាង ២ ០០០ មម ហើយមានជម្រាលខ្លាំង ទាមទារឱ្យមានការរៀបចំដីជាថ្នាក់ៗ ឬក៏ប្រើវិធានការណ៍ផ្សេងៗទៀត។ ការងារនេះអាស្រ័យទៅលើតម្រូវការនៃការគ្រប់គ្រង តម្លៃនៃប្រភេទឈើដាំ និងចំណាយសម្រាប់ពលកម្មក្នុងការដាំឈើ។

### ៣.៣.៣ កត្តាដី

–ប្រភេទដី

ដីមមោក និងដីល្បាប់ជ្រៅជាប្រភេទដីល្អបំផុតសម្រាប់ដាំឈើ។ ដីមមោក ជារឿយៗច្រើនជួបប្រទះនៅផ្នែកខាងក្រោមនៃជម្រាលដែលកើតឡើងពីការប្រមូលផ្តុំនៃដី និងកម្ទេចកម្ទីរុក្ខជាតិ។ ដីល្បាប់កើតឡើងពីកម្ទេចកំណដែលរងធ្លាក់នៅស្រទាប់ក្រោមនៃផ្ទៃទឹក ដែលជាទូទៅរួមផ្សំដោយភក់ និងដីឥដ្ឋ។ ដីដែលនៅពាក់កណ្តាលជម្រាលក៏សមស្របសម្រាប់ដាំឈើផងដែរ។ នៅក្នុងតំបន់ដែលមានស្រទាប់ថ្មបាយក្រៀមនៅក្បែរផ្ទៃដី បង្កការលំបាកដល់ការចាក់ឫស ចុះទៅក្រោម ហើយដីប្រភេទនេះមិនសមស្របចំពោះការដាំឈើជាលក្ខណៈពាណិជ្ជកម្មទេ។

–រចនាសម្ព័ន្ធដី

ដីដែលសមស្របបំផុតសម្រាប់ការងារដាំឈើគឺជាប្រភេទដីល្បាប់ដែលមានវាយនភាពមធ្យម។ ដីខ្សាច់ ដីឥដ្ឋ និងដីហាប់ មិនសមស្របសម្រាប់ការងារដាំឈើទេ។ ដីដែលមានរចនាសម្ព័ន្ធដីអន់ ឬដីជាំទឹក អាចកែលម្អបានដោយការជីកប្រឡាយបង្ហូរទឹក ដើម្បីបន្ថយកម្ពស់ទឹកក្រោមដី។

–ជីជាតិដី

ដីល្បាប់មិនមែនជានិច្ចកាលសុទ្ធតែមានជីជាតិទេ ការដាក់ជីគឺជាការចាំបាច់។ នៅក្នុងតំបន់ដែលមានកម្ទេចកំណច្រើនពេកអាចមានកង្វះសារធាតុចិញ្ចឹមក្នុងរយៈពេលបណ្តោះអាសន្នមួយ។ នៅក្នុងតំបន់ដែលមានបរិមាណទឹកភ្លៀងខ្ពស់ក៏អាចមានកង្វះសារធាតុចិញ្ចឹម ជាពិសេសចំពោះប្រភេទដីខ្សាច់។ សម្រាប់ប្រភេទដីខ្សាច់ គេត្រូវដាក់ជីសរីរាង្គដើម្បីបង្កើនជីជាតិដី និង រចនាសម្ព័ន្ធដី។

–ដីអាស៊ីត

ដីដែលមិនមានកម្រិតអាស៊ីតខ្លាំងពេក ឬបាសខ្លាំងពេក (ណឺត) សមស្របបំផុតសម្រាប់ការងារដាំឈើ។ ដីដែលមានអាស៊ីតតិចតួច ឬ អាល់កាឡាំងតិចតួចក៏សមស្របសម្រាប់ការងារដាំឈើផងដែរប្រសិនបើគេជ្រើសរើសប្រភេទឈើឱ្យបានសមស្របសម្រាប់លក្ខខណ្ឌនេះ។

## ៣.៤ ការធ្វើផែនការដាំដុះ

ផែនការដាំដុះ និងការថែទាំចម្ការឈើ គឺតម្រូវឱ្យកម្មសិទ្ធករព្រៃឯកជន រៀបចំក្នុងករណីផ្ទៃដីស្នើសុំចុះបញ្ជីព្រៃឯកជនមានទំហំលើសពី១០ហិកតា ហើយការរៀបចំត្រូវមានចំណុចសំខាន់ៗដូចបង្ហាញក្នុងគំរូខាងក្រោម៖

## គំរូ
# ផែនការដាំឈើជាចម្ការព្រៃឯកជន

១-សេចក្តីផ្តើម

២-គោលបំណង

៣-ស្ថានភាពនៃទីតាំងដាំឈើ

ម្ចាស់ព្រៃឯកជនត្រូវបង្ហាញអំពីស្ថានភាពនៃទីតាំងដែលត្រូវបានជ្រើសរើសសម្រាប់ដាំឈើ រួមមាន៖

- ស្ថានភាពប្រើប្រាស់ដី និងទំហំផ្ទៃដីចម្ការឈើ
- ភូមិសាស្ត្រ៖ ភូមិ..........ឃុំ...............ស្រុក.................ខេត្ត
- ផែនទី និងបង្ហាញចំណុចនិយាមកា
- ប្រភេទដី និងព័ត៌មានដូចជា បរិមាណទឹកភ្លៀង និងធាតុអាកាសជាដើម (បើអាច)

៤-វិធីសាស្ត្រ និងការប្រតិបត្តិ

៤.១ ការរៀបចំដី និងប្លុកដាំដុះ

៤.២ ប្រភេទឈើ និងប្រភពពូជ

៤.៣ គម្លាតនៃការដាំ

៤.៤ ការថែទាំ (ធ្វើស្មៅ និងផ្លូវភ្លើង)

៥-ការរៀបចំផែនការប្រតិបត្តិ

| ល.រ | សកម្មភាព | ពេលវេលា | ផ្សេងៗ |
|---|---|---|---|
| ១ | ការសិក្សា និងវាយតម្លៃទីតាំង | | |
| ២ | ការជ្រើសរើស និងត្រៀមកូនឈើដាំ | | |
| ៣ | ការរៀបចំដី | | |
| ៤ | ការងារដាំដុះ | | |
| ៥ | ការងារថែទាំ | | |
| ៦ | ..................................... | | |
| ៧ | ..................................... | | |
| ៨ | ..................................... | | |
| ៩ | ..................................... | | |
| ១០ | ..................................... | | |

៦-ការតាមដាន ពិនិត្យ និងវាយតម្លៃ

### ៣.៥ ការតាមដាន ពិនិត្យ និងវាយតម្លៃ

ម្ចាស់ព្រៃឯកជនត្រូវធ្វើការពិនិត្យចម្ការឈើដាំរបស់ខ្លួនជាប្រចាំ បន្ទាប់ពីដាំរួច ដើម្បីតាមដានស្ថានភាពលូតលាស់នៃកូនឈើ និងកំណត់ពេលវេលាធ្វើការដាំជួសជាដើម។ ម្ចាស់ព្រៃឯកជនអាចស្នើសុំប្រឹក្សាយោបល់ ឬជំនួយបច្ចេកទេសពីមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្នុងករណីចាំបាច់ ដើម្បីធានាថា ចម្ការឈើដាំគឺមានគុណភាព និងអនុលោមតាមលក្ខណៈបច្ចេកទេស។

### ៣.៦ កំណត់ត្រា និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន

ម្ចាស់ព្រៃឯកជនត្រូវចូលរួមសហការជាមួយរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច តាមរយៈការរាយការណ៍រៀងរាល់ត្រីមាសអំពីស្ថានភាពវិវត្តន៍ចម្ការព្រៃឯកជនរបស់ខ្លួន ដោយរាប់បញ្ចូលទាំង អត្រារស់ សកម្មភាពថែទាំ ការលូតលាស់ និងប្រភេទឈើផ្សេងៗទៀតដែលទើបបានដាំបញ្ចូល ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យចម្ការព្រៃឯកជន។

## ជំពូកទី ៤
## ការប្រមូលផល និងយន្តការនៃការត្រួតពិនិត្យចម្ការឈើដាំ និងព្រៃឯកជន

ជំពូកនេះគឺបង្ហាញអំពីនីតិវិធីនៃការស្នើសុំការប្រមូលផលឈើ និងយន្តការនៃការត្រួតពិនិត្យចម្ការឈើដាំដែលកម្មសិទ្ធិករព្រៃឯកជនត្រូវប្រតិបត្តិ ព្រមទាំងរបៀបនៃការកត់ត្រាអំពីសកម្មភាពនៃការដាំដុះឈើ ការថែទាំ និងបរិមាណឈើដែលត្រូវប្រមូលផលចុះក្នុងសៀវភៅបន្ទុក ព្រមទាំងរាយការណ៍អំពីសកម្មភាពប្រមូលផល និងបរិមាណប្រមូលផលឈើដល់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច។

### ៤.១ ប្រតិបត្តិការប្រមូលផល

ការប្រមូលផលជាដំណាក់កាលដែលម្ចាស់ព្រៃឯកជន ត្រូវគិតគូរជាមុនអំពីសកម្មភាពដូចជា ប្រតិបត្តិការប្រមូលផល ទីផ្សារ និងការដឹកជញ្ជូនទៅកាន់ទីតាំងប្រើប្រាស់ ចែកចាយ និងកែច្នៃ។ ដំណាក់កាលនេះ ម្ចាស់ព្រៃឯកជនត្រូវគិតពិចារណាការរៀបចំផែនការប្រមូលផល មានដូចខាងក្រោម៖

- ជ្រើសរើសប្រព័ន្ធរុក្ខវប្បកម្មសម្រាប់អនុវត្ត
- ជ្រើសរើសប្រព័ន្ធនៃការធ្វើអាជីវកម្មប្រមូលផលដែលសមស្រប
- ជ្រើសរើសឧបករណ៍ និងសម្ភារសម្រាប់ធ្វើការប្រមូលផល ការអូសទាញ និងការកែច្នៃ
- រៀបចំផែនការកសាងផ្លូវអូសទាញ និងការដឹកជញ្ជូន




ដ្យាក្រាម ៤.១ ការធ្វើអាជីវកម្មប្រមូលផលព្រៃឯកជន

ម្ចាស់ព្រៃឯកជនដែលបានចុះបញ្ជីព្រៃឯកជនរួច មានសិទ្ធិក្នុងការប្រមូលផល ប្រើប្រាស់ និងធ្វើអាជីវកម្មផលអនុផលព្រៃឈើ និងផលិតផលឈើកែច្នៃ ដែលមានប្រភពចេញពីព្រៃឯកជនរបស់ខ្លួន ដោយអនុវត្តតាមវិធានដូចខាងក្រោម៖

### *៤.១.១ មុនពេលប្រតិបត្តិការ*

ម្ចាស់ព្រៃឯកជនត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរមករដ្ឋបាលព្រៃឈើមានសមត្ថកិច្ច អំពីទីតាំងឡូត៍ ប្រមូលផល ទំហំផ្ទៃដី និងប្រភេទឈើដែលត្រូវប្រមូលផល យ៉ាងតិចពីរសប្តាហ៍មុនពេលប្រតិបត្តិការប្រមូលផលចាប់ផ្តើម។ ក្នុងករណីព្រៃឯកជនដែលមានទំហំចាប់ពី១០ហិកតាឡើង ម្ចាស់ព្រៃឯកជនត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពប្រមូលផលដោយមានភ្ជាប់មកជាមួយនូវផែនទីបង្ហាញទីតាំងឡូត៍ និងទិសដៅនៃការដឹកជញ្ជូនទៅកាន់ទីផ្សារប្រើប្រាស់ ឬ ចែកចាយជាដើម។

### *៤.១.២ ការចាប់ផ្តើមប្រតិបត្តិការប្រមូលផល*

នៅពេលចាប់ផ្តើមប្រតិបត្តិការប្រមូលផល ម្ចាស់ព្រៃឯកជន ត្រូវកត់ត្រាក្នុងសៀវភៅបន្ទុកព្រៃឯកជនរបស់ខ្លួននូវទីតាំងឡូត៍ប្រមូលផល ទំហំផ្ទៃដីប្រមូលផល បរិមាណឈើ ឬផល អនុផលដែលបានប្រមូល និងដែលបានដឹកចេញពីចម្ការព្រៃឯកជនរបស់ខ្លួនសម្រាប់ការកែច្នៃផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងនាំចេញ។

ក្នុងដំណើរការប្រមូលផល ម្ចាស់ព្រៃឯកជនត្រូវអនុវត្តតាមក្រមបច្ចេកទេសអនុវត្តប្រមូលផលនៅកម្ពុជា ដើម្បីប្រាកដថា ការធ្វើអាជីវកម្មប្រមូលផលព្រៃឯកជនរបស់ខ្លួនធានាបាននូវ៖

- សុវត្ថិភាពចំពោះកម្មករ ក្នុងអំឡុងពេលកាប់រំលំ
- កាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន និងសង្គមក្នុងកម្រិតអប្បបរមា
- ការប្រើប្រាស់មធ្យោបាយអូសទាញ និងដឹកជញ្ជូនសមស្របមិនបង្កការខូចខាតដល់ប្រព័ន្ធផ្លូវថ្នល់ ឬការហូរច្រោះ
- ការប្រើប្រាស់ផលឈើអស់លទ្ធភាព និងកាត់បន្ថយកាកសំណល់ឈើក្រោយពេលប្រមូលផល ដែលជាហេតុបង្កឱ្យមានជំងឺ សត្វល្អិតបំផ្លាញ ឬ ភ្លើងព្រៃជាដើម

រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចនៃមូលដ្ឋានសាមីត្រូវគ្រប់គ្រងសំណុំឯកសារព្រៃឯកជននីមួយៗ ដែលបានចុះបញ្ជី និងមានសិទ្ធិត្រួតពិនិត្យសៀវភៅបន្ទុកព្រៃឯកជនណាមួយតាមការចាំបាច់ ឬក្នុងករណីសង្ស័យ ដើម្បីផ្ទៀងផ្ទាត់សកម្មភាពប្រមូលផល និងការធ្វើអាជីវកម្មរបស់សិទ្ធិវន្តព្រៃឯកជននោះ។




ដ្យាក្រាម ៤.២ ដំណើរការពិនិត្យ និងផ្ទៀងផ្ទាត់ការប្រមូលផលព្រៃឯកជន

## ៤.២ យន្តការនៃការពិនិត្យចម្ការឈើដាំ និងព្រៃឯកជន

យន្តការនៃការពិនិត្យចម្ការឈើដាំ និងព្រៃឯកជន នៅក្នុងជំពូកនេះសំដៅដល់ក្រោយពេលទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន សិទ្ធិវន្តព្រៃឯកជនសាមីអាចស្នើសុំជំនួយបច្ចេកទេសសម្របសម្រួល ឬសហការជាមួយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្នុងការថែទាំចម្ការព្រៃដាំ និងគ្រប់គ្រងចម្ការព្រៃដាំ ដោយផ្អែកតាមបច្ចេកទេសវក្ខវប្បកម្មដែលកំណត់ក្នុងផែនការដាំដុះបង្កើតព្រៃឯកជន ឬ ផែនការអភិវឌ្ឍន៍ព្រៃឯកជនរបស់ខ្លួនរហូតដល់អាយុប្រមូលផល។ សិទ្ធិវន្តព្រៃឯកជននីមួយៗដែលបានចុះបញ្ជីព្រៃឯកជនស្របតាមវិធាននៃប្រកាសនេះ មានភារកិច្ចទទួលខុសត្រូវកត់ត្រាចុះក្នុងសៀវភៅបន្ទុកនូវរាល់សកម្មភាពក្នុងការប្រមូលផល និងការធ្វើអាជីវកម្មឈើដាំរបស់ខ្លួនរួមមានទិន្នន័យបរិមាណឈើ ដឹកជញ្ជូន កែច្នៃ ធ្វើពាណិជ្ជកម្ម ឬប្រើប្រាស់។

ការត្រួតពិនិត្យចម្ការឈើដាំ និងព្រៃឯកជន ត្រូវអនុវត្តដោយសិទ្ធិវន្តព្រៃឯកជនសាមី និង/ឬ មន្ត្រីជំនាញនៃរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច។ ការបង្កើតយន្តការត្រួតពិនិត្យចម្ការឈើដាំ និងព្រៃឯកជននៅក្នុងជំពូកនេះគឺពុំមានន័យសំដៅដល់ការដាក់សម្ពាធដល់សិទ្ធិវន្តព្រៃឯកជនសាមីនោះឡើយ គោលគំនិតសំខាន់គឺរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ផ្តល់សេវាកម្មគាំទ្របច្ចេកទេស និងការតម្រង់ទិសផ្នែកបច្ចេកទេសដល់កម្មសិទ្ធិករ តាមរយៈការផ្តល់សេវាបណ្តុះបណ្តាលជំនាញបច្ចេកទេសដាំឈើ និងការគ្រប់គ្រងចម្ការព្រៃដាំតាំងពីដាំដុះរួចរហូតដល់បង្កើតបានជាចម្ការព្រៃដាំពេញលក្ខណៈ និងការប្រមូលផលជាដើម។




ដ្យាក្រាម ៤.៣ គោលគំនិតនៃការពិនិត្យចម្ការឈើដាំ និងព្រៃឯកជន

តាមដ្យាក្រាម ៤.៣ ខាងលើ បង្ហាញថា ការងារដាំឈើជាចម្ការទាមទារឱ្យមានការយកចិត្តទុកដាក់ក្នុងការថែទាំតាំងពីការដាំដុះរហូតដល់ចម្ការឈើគ្រប់អាយុប្រមូលផល។ ការលូតលាស់ និងការប្រែប្រួលនៃចម្ការឈើមានបួនដំណាក់កាលសំខាន់ៗ ដូចជាការដាំដុះ ការលូតលាស់ប្រជែងគ្នា ការវិវត្តទៅជាចម្ការឈើពេញវ័យ និងចម្ការឈើចាស់ ឬ

គ្រប់អាយុប្រមូលផល។ ដំណាក់កាលនីមួយៗចាំបាច់ទាមទារឱ្យកម្មសិទ្ធិករព្រៃឯកជនអនុវត្តការងារថែទាំ តាមដាន និងពិនិត្យយ៉ាងម៉ត់ចត់។ ដូច្នេះ កម្មសិទ្ធិករព្រៃឯកជនអាចសហការជាមួយមន្ត្រីជំនាញនៃរដ្ឋបាលព្រៃឈើក្នុងការតាមដាន និងពិនិត្យស្ថានភាពដុះលូតលាស់នៃដើមឈើ ដើម្បីទទួលបាននូវការប្រឹក្សាយោបល់ ការតម្រង់ទិសផ្នែកបច្ចេកទេស ការផ្តល់សេវាបណ្តុះបណ្តាលជំនាញបច្ចេកទេសដាំឈើ និងការគ្រប់គ្រងចម្ការព្រៃដាំជាដើម។

ដោយហេតុថា ប្រភេទឈើ និងចំនួនដើមឈើដែលបានដាំក្នុងចម្ការឈើ និងព្រៃឯកជនត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់រដ្ឋបាលព្រៃឈើនៅពេលស្នើសុំចុះបញ្ជីព្រៃឯកជន ដូច្នេះកម្មសិទ្ធិករព្រៃឯកជនគួរកត់ត្រានូវសកម្មភាពនានា ដែលបានអនុវត្តដូចជាការធ្វើរហាលនៅដំណាក់កាលលូតលាស់ប្រកួតប្រជែង ការដកហូតបរិមាណ ៥០% នៅពេលចម្ការឈើពេញវ័យ និងការប្រមូលផល១០០% នូវផលឈើដាំនៅពេលចម្ការឈើដល់អាយុប្រមូលផល។ ព័ត៌មានទាំងនេះ គួរត្រូវបានផ្តល់ជូនមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដើម្បីកាត់ចេញនូវបរិមាណស្តុកផលឈើដែលបានដាំចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរដ្ឋបាលព្រៃឈើ។ ព័ត៌មានទាំងនោះត្រូវធ្វើការកត់ត្រាចូលក្នុងសៀវភៅបន្ទុកដែលរដ្ឋបាលព្រៃឈើបានផ្តល់ជូនជាមួយនឹងវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជនដែលឯកសារទាំងពីរនេះ និងប្រើប្រាស់សម្រាប់ការដឹកជញ្ជូនផលិតផលឈើចេញពីចម្ការឈើទៅកាន់ទីផ្សារប្រើប្រាស់។

### ៤.២.១ ការតាមដាន និងពិនិត្យដោយសិទ្ធិវន្តព្រៃឯកជន

សិទ្ធិវន្តព្រៃឯកជនត្រូវតាមដាន ពិនិត្យ និងកត់ត្រានូវរាល់សកម្មភាពទាំងឡាយពាក់ព័ន្ធនឹងចម្ការព្រៃឯកជនដូចជា៖

- កាលបរិច្ឆេទនៃការដាំដុះដើមឈើ ប្រភេទឈើ ចំនួនដើមឈើ និង/ឬទំហំផ្ទៃដី (ហិកតា)
- លទ្ធផលនៃការដាំដុះដូចជាអត្រារស់ និងការលូតលាស់ផ្នែកអង្កត់ផ្ចិត កម្ពស់ និងកន្សោមស្លឹកជាដើម
- ការក្រីមែក និងការធ្វើរហាលចម្ការឈើដាំ និង/ឬ ព្រៃឯកជន ដោយបង្ហាញអំពីបរិមាណឈើដែលបានដកហូតពីសកម្មភាព និងបរិមាណផលឈើដែលទទួលបាន
- បរិមាណផលឈើដែលបានធ្វើការប្រមូលផលតាមប្លុក និងទិសដៅនៃការចែកចាយទៅកាន់ទីផ្សារ
- បរិមាណ និងប្រភេទឈើដែលបានដាំដុះឡើងវិញ ឬ ខ្នែងគល់ដែលបានដុះឡើងវិញ

### ៤.២.២ ការកត់ត្រាចុះក្នុងសៀវភៅបន្ទុក

ម្ចាស់ព្រៃឯកជនមានកាតព្វកិច្ចកត់ត្រាចុះក្នុងសៀវភៅបន្ទុកព្រៃឯកជនប្រចាំឆ្នាំនូវរាល់សកម្មភាពគ្រប់គ្រងព្រៃឯកជនរបស់ខ្លួនសម្រាប់ការតាមដាន ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ឬការផ្តល់អន្តរាគមន៍គាំទ្រផ្នែកបច្ចេកទេសរបស់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច។

សកម្មភាពព្រៃឯកជន ត្រូវបានចុះកំណត់ត្រាតាមដំណាក់កាលប្រចាំខែនីមួយៗនៅក្នុងឆ្នាំប្រតិបត្តិការដូចខាងក្រោម៖

**១-កំណត់ត្រាដំណើរការបង្កើតព្រៃឯកជន៖** រួមមានសកម្មភាពចាប់ផ្តើមពីការរៀបចំទីកន្លែងថ្នាលបណ្តុះការបំប៉នកូនឈើ ការដាំដុះនៅលើចម្ការ ការថែទាំ ការអនុវត្តបច្ចេកទេសរុក្ខវប្បកម្មលើដំណុះព្រៃរហូតដល់ដំណាក់កាលមុនពេលប្រមូលផល។

**២-កំណត់ត្រាដំណើរការប្រមូលផលព្រៃឯកជន៖** រួមមាន ការងារកាប់រំលំ ការកាត់តម្រឹម ការអូសទាញការគរជាគំនរ និងការធ្វើអនាម័យព្រៃក្រោយពេលប្រមូលផល ព្រមទាំងព័ត៌មាននៃការដឹកជញ្ជូនចេញពីគំនរឆ្ពោះទៅទិសដៅប្រើប្រាស់ទីផ្សារ រោងសន្និធិសម្រាប់លក់ ចូលរោងចក្រ ឬសិប្បកម្មកែច្នៃ ឬទិសដៅនាំចេញ។

## អត្តសញ្ញាណព្រៃឯកជន

ព្រៃឯកជន ឬចម្ការឈើដែលជាកម្មវត្ថុនៃសៀវភៅបន្ទុកនេះ មានអត្តសញ្ញាណលម្អិតដូចខាងក្រោម៖

១-ឈ្មោះម្ចាស់ព្រៃឯកជន ៖

២-ថ្ងៃខែឆ្នាំកំណើត ៖.................................... សញ្ជាតិ ...........................

៣-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន៖...................................................................................

ចុះថ្ងៃទី......... ខែ................. ឆ្នាំ..........................

៤-មុខរបរ ៖ ...................................................................................

៥-ចម្ការឈើដាំ ៖ ☐គ្រួសារ ☐ឯកជន ☐ក្រុមហ៊ុន ឬនីតិបុគ្គល

៦-អាសយដ្ឋានអចិន្ត្រៃយ៍ ៖ ...................................................................................

...................................................................................................................

ទូរស័ព្ទ/ទូរសារ......................................................... អ៊ីម៉ែល...................................................

គេហទំព័រ...................................................................................................................

៧-ប្រភេទព្រៃឯកជន ៖

☐ព្រៃឯកជនលក្ខណៈគ្រួសារ ☐ព្រៃឯកជនទំហំតូច

☐ព្រៃឯកជនទំហំមធ្យម ☐ព្រៃឯកជនទំហំធំ

៨-ប្រភេទឈើដាំ(ឈ្មោះក្នុងស្រុក និងឈ្មោះវិទ្យាសាស្ត្រ)៖

(១)-ប្រភេទ...................................................................................................

(២)-ប្រភេទ ...................................................................................................

(៣)-ប្រភេទ ...................................................................................................

(៤)-ប្រភេទ...................................................................................................

...................................................................................................................

៩-ទំហំព្រៃឯកជនសរុប ៖.........................................................ហិកតា

១០-ទំហំព្រៃឯកជនតាមប្រភេទ ឬតាមទីតាំង(បើសិនជាមាន)

(១)-ទីតាំង ក ៖ ............................................................................... ហិកតា

(២)-ទីតាំង ខ ៖ ............................................................................... ហិកតា

(៣)-ទីតាំង គ ៖............................................................................... ហិកតា

...................................................................................................................

...................................................................................................................

១១-ព្រំប្រទល់ព្រៃឯកជន (ភ្ជាប់ជាមួយប្លង់ ឬផែនទីសម្គាល់ )

ក-ព្រំប្រទល់រួមព្រៃឯកជន៖

...................................................................................................................

...................................................................................................................

## អត្តសញ្ញាណព្រៃឯកជន

ខ-ព្រំប្រទល់ព្រៃឯកជនតាមទីតាំង៖

(១)-ទីតាំង ក ៖

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

(២)-ទីតាំង ខ ៖

..................................................................................................................................

..................................................................................................................................

..................................................................................................................................

(៣)-ទីតាំង គ ៖

..................................................................................................................................

..................................................................................................................................

១២-អនុញ្ញាតឱ្យបង្កើត និងចុះបញ្ជីព្រៃឯកជនតាមរយៈលិខិត/វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជនលេខ................................... ចុះថ្ងៃទី......... ខែ..............ឆ្នាំ............ចេញដោយរដ្ឋបាលព្រៃឈើ

## គំរូកំណត់ត្រា ដំណើរការបង្កើតព្រៃឯកជន

ប្រចាំខែ........................ ឆ្នាំ.......................

| កាលបរិច្ឆេទ | កំណត់ត្រាសកម្មភាព | ដង់ស៊ីតេ (ដើម/ហ.ត) | ផ្ទៃដីដាំដុះ (ហ.ត) | កំណត់សម្គាល់ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

កំណត់សម្គាល់របស់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច
លើដំណើរការបង្កើតព្រៃឯកជន

យោងលិខិតបញ្ជាបេសកកម្មលេខ......................ចុះថ្ងៃទី......... ខែ.......... ឆ្នាំ..............

មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដឹកនាំបេសកកម្មឈ្មោះ................................................

ឋានៈ...................................................បានត្រួតពិនិត្យ វាយតម្លៃ និងធ្វើកំណត់សម្គាល់លើលទ្ធផលនៃដំណើរការបង្កើតព្រៃឯកជនដូចខាងក្រោម៖

.....................................................................................................................

.....................................................................................................................

.....................................................................................................................

.....................................................................................................................

.....................................................................................................................

កាលបរិច្ឆេទត្រួតពិនិត្យ ៖.....................................................................

ហត្ថលេខា និងឈ្មោះមន្ត្រីដឹកនាំបេសកកម្ម ៖.....................................................................

## គំរូកំណត់ត្រាដំណើរការប្រមូលផលព្រៃឯកជន

-----<<<>>>-----

ប្រចាំខែ........................ ឆ្នាំ.......................

| កាលបរិច្ឆេទ | កំណត់ត្រាសកម្មភាព | ប្លុកអាជីវកម្ម | ចំនួន (ដើម) | បរិមាណ (ស្ទែរ ឬ ម៣) | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

កំណត់សម្គាល់របស់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច
លើដំណើរការប្រមូលផលព្រៃឯកជន

-----<<<>>>-----

យោងលិខិតបញ្ជាបេសកកម្មលេខ.......................ចុះថ្ងៃទី......... ខែ........... ឆ្នាំ...............
មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដឹកនាំបេសកកម្ម ឈ្មោះ.................................................
ឋានៈ...................................................បានត្រួតពិនិត្យ វាយតម្លៃ និងធ្វើកំណត់សម្គាល់លើលទ្ធផលនៃដំណើរការបង្កើតព្រៃឯកជនដូចខាងក្រោម៖

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

កាលបរិច្ឆេទត្រួតពិនិត្យ ៖.................................................................

ហត្ថលេខា និងឈ្មោះមន្ត្រីដឹកនាំបេសកកម្ម ៖

### ៤.៣ ការតាមដាន និងការពិនិត្យការអនុវត្ត

មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវតាមដាន និងត្រួតពិនិត្យលើការអនុវត្តការងារប្រមូលផលឈើនៅក្នុងចម្ការឈើដាំ និងព្រៃឯកជន ក្នុងនោះអាចត្រួតពិនិត្យលើឯកសារចាំបាច់នានាដូចជា វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន ព័ត៌មានកត់ត្រាចុះក្នុងសៀវភៅបន្ទុក និងប្លុកទីតាំងធ្វើការប្រមូលផលជាដើម។

ក្នុងករណីចាំបាច់ មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចនឹងធ្វើការចុះត្រួតពិនិត្យដល់ទីតាំងប្លុកកាប់ប្រមូលផលនៅទីវាលជាក់ស្តែងតែម្តង ប្រសិនបើកម្មសិទ្ធិករព្រៃឯកជនពុំបានអនុវត្តការងារកត់ត្រា ឬ បំពេញការកត់ត្រាទិន្នន័យតាមការណែនាំដូចមានចែងក្នុងប្រការនៃសៀវភៅបន្ទុក។ គំរូសៀវភៅបន្ទុកដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ១ នៃគោលការណ៍ណែនាំ។

# ឯកសារយោង


១ នាយកដ្ឋានរុក្ខា-ប្រមាញ់ (១៩៩៩) ក្រមបច្ចេកទេសអនុវត្តប្រមូលផលព្រៃឈើនៅកម្ពុជា។ នាយកដ្ឋានរុក្ខា-ប្រមាញ់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២ នាយកដ្ឋានរុក្ខា-ប្រមាញ់ (១៩៩៩) គោលការណ៍ណែនាំសម្រាប់គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ នាយកដ្ឋានរុក្ខា-ប្រមាញ់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣ រាជរដ្ឋាភិបាលកម្ពុជា (២០០២) ច្បាប់ស្តីពីព្រៃឈើ។

៤ រាជរដ្ឋាភិបាលកម្ពុជា (២០១០) កម្មវិធីព្រៃឈើជាតិ ២០១០-២០២៩។

៥ រាជរដ្ឋាភិបាលកម្ពុជា (២០១៨) ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០។

៦ នាយកដ្ឋានរុក្ខា-ប្រមាញ់ (២០០៣) បច្ចេកទេសដាំឈើសម្រាប់កសិករ៖ ការណែនាំងាយៗ-ពីគ្រាប់ពូជរហូតកើតបានជាដើមឈើ។

៧ រដ្ឋបាលព្រៃឈើ (២០០២) គោលការណ៍ណែនាំសម្រាប់កំណត់ទីតាំង និងការអនុវត្តការងារដាំដើមឈើ។ គម្រោងគាំទ្រ ការកសាងគោលនយោបាយវិស័យគ្រាប់ពូជឈើ។ កិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលព្រៃឈើ និងគម្រោងគ្រាប់ពូជឈើកម្ពុជា។

៨ រដ្ឋបាលព្រៃឈើ (២០០៥) សេចក្តីណែនាំការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ។

៩ M. DE ZOYSA, K. P. ARIYADASA & Y. Y. K. DE SILVA (2002). Private Forest Plantation Development in Sri Lanka: Issues and Challenges. Paper presented at the IUFRO Science/Policy Interface Task Force regional meeting held in Chennai, India at the M.S. Swaminathan Research Foundation, 16-19 July 2002.

១០Swoyambhu M. Amatya, and Prakash Lamsal (2017). Private Forests in Nepal: Status and Policy Analysis. Department of Forests, Government of Nepal. Journal of Forest and Livelihood 15(1) September, 2017.

១១Northern New South Wales Forestry Services (2002). The private native forest and plantation resources. NSW Department of State and Regional Development and Agriculture Fisheries and Forestry Australia


### *ឯកសារលិខិតបទដ្ឋានគតិយុត្ត៖*

- អនុក្រឹត្យលេខ ៥៣អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពី នីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- អនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨ ស្តីពី វិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃឈើរបស់រដ្ឋសម្រាប់ការដាំឈើ
- ប្រកាសលេខ៣២៧ប្រក.កសក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី “វិធានព្រៃឯកជន”

ឧបសម្ព័ន្ធ ១៖ គំរូសៀវភៅបន្ទុក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**រដ្ឋបាលព្រៃឈើ**
លេខ៖................រព.នពជ

# សៀវភៅបន្ទុក
# ព្រៃឯកជន

ខែ....... ឆ្នាំ២០......

## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១**.-

សៀវភៅបន្ទុកព្រៃឯកជនត្រូវបានបង្កើតឡើង ដើម្បីប្រើប្រាស់សម្រាប់កត់ត្រានូវរាល់សកម្មភាពអាជីវកម្មប្រមូលផលព្រៃឯកជនរបស់សាមីម្ចាស់ព្រៃឯកជន ដែលបានចុះបញ្ជីដោយអនុលោមទៅតាមប្រការ១៦ ជំពូកទី៣ នៃប្រកាសលេខ៣២៧ ប្រក.កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីវិធានព្រៃឯកជន។

**ប្រការ ២**.-

សៀវភៅបន្ទុកព្រៃឯកជនមានគោលដៅ៖

- សម្រួលដល់ម្ចាស់ព្រៃឯកជនក្នុងការប្រមូល ការកែច្នៃ និងការធ្វើពាណិជ្ជកម្មផល អនុផលព្រៃឈើ ដែលមានប្រភពចេញពីព្រៃឯកជនរបស់ខ្លួន
- ប្រើប្រាស់ជាមូលដ្ឋានទិន្នន័យសម្រាប់មន្ត្រីមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លើការប្រមូលផល ការដឹកជញ្ជូន ការកែច្នៃ និងការធ្វើពាណិជ្ជកម្ម របស់ម្ចាស់ព្រៃឯកជន។

**ប្រការ ៣**.-

សៀវភៅបន្ទុកនេះ អនុវត្តចំពោះព្រៃឯកជន ដែលបានចុះបញ្ជីរួច ដោយអនុលោមតាមប្រកាសស្តីពីវិធានព្រៃឯកជន។

## ជំពូកទី២
## អត្តសញ្ញាណព្រៃឯកជន

**ប្រការ៤**.-

ព្រៃឯកជន ឬចម្ការឈើដែលជាកម្មវត្ថុនៃសៀវភៅបន្ទុកនេះ មានអត្តសញ្ញាណលម្អិត ដូចខាងក្រោម៖

១-ឈ្មោះម្ចាស់ព្រៃឯកជន ៖

២-ថ្ងៃខែឆ្នាំកំណើត ៖ ...................................... សញ្ជាតិ

៣-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន៖ ......................................................................

ចុះថ្ងៃទី......... ខែ................ ឆ្នាំ..........................

៤-មុខរបរ ៖ ..............................................................................

៥-☐គ្រួសារ ☐ឯកជន ☐ក្រុមហ៊ុន ឬនីតិបុគ្គល៖......................................................................

៦-អាសយដ្ឋានអចិន្ត្រៃយ៍ ៖..............................................................................

..............................................................................................................................

ទូរស័ព្ទ/ទូរសារ ......................................................... អ៊ីម៉េល ...............................................

គេហទំព័រ...........................................................................................................................

៧-ប្រភេទព្រៃឯកជន ៖

☐ព្រៃឯកជនលក្ខណៈគ្រួសារ ☐ព្រៃឯកជនទំហំតូច

☐ព្រៃឯកជនទំហំមធ្យម ☐ព្រៃឯកជនទំហំធំ

៨-ប្រភេទឈើដាំ(ឈ្មោះក្នុងស្រុក និងឈ្មោះវិទ្យាសាស្ត្រ)៖

(១)-ប្រភេទ ..............................................................................................................

(២)-ប្រភេទ ..............................................................................................................

(៣)-ប្រភេទ ..............................................................................................................

(៤)-ប្រភេទ ..............................................................................................................

(៥)-ប្រភេទ ..............................................................................................................

..............................................................................................................

..............................................................................................................

៩-ទំហំព្រៃឯកជនសរុប ៖...... ...................................................... ....ហិកតា

១០-ទំហំព្រៃឯកជនតាមប្រភេទ ឬតាមទីតាំង(បើសិនជាមាន)

(១)-ទីតាំង ក ៖..........................................................................................ហិកតា

(២)-ទីតាំង ខ ៖ .........................................................................................ហិកតា

(៣)-ទីតាំង គ ៖..........................................................................................ហិកតា

..............................................................................................................................

១១-ព្រំប្រទល់ព្រៃឯកជន (ភ្ជាប់ជាមួយប្លង់ ឬផែនទីសម្គាល់ )

ក-ព្រំប្រទល់រួមព្រៃឯកជន៖

..............................................................................................................................

..............................................................................................................................

ខ-ព្រំប្រទល់ព្រៃឯកជនតាមទីតាំង៖

(១)-ទីតាំង ក ៖

..............................................................................................................................

..............................................................................................................................

(២)-ទីតាំង ខ ៖

..............................................................................................................................

..............................................................................................................................

(៣)-ទីតាំង គ ៖

..............................................................................................................................

..............................................................................................................................

១២-អនុញ្ញាតឱ្យបង្កើត និងចុះបញ្ជីព្រៃឯកជនតាមរយៈលិខិត/វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន លេខ.................................... ចុះថ្ងៃទី......... ខែ..............ឆ្នាំ............ចេញដោយរដ្ឋបាលព្រៃឈើ

-----៚✷៚-----

## ផ្នែកទី៣
## ការធ្វើអាជីវកម្មប្រមូលផលព្រៃឯកជន

**ប្រការ ៥**.-

ម្ចាស់ព្រៃឯកជនមានសិទ្ធិប្រមូលផលព្រៃឯកជនសាមី ដោយមិនតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតប្រមូលផលឡើយ។ ម្ចាស់ព្រៃឯកជនត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរមកខណ្ឌរដ្ឋបាលព្រៃឈើនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី យ៉ាងតិចក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ មុនពេលប្រតិបត្តិការប្រមូលផលចាប់ផ្តើម ដោយបញ្ជាក់នូវ៖

- កាលបរិច្ឆេទនៃការប្រមូលផល ទីតាំង ទំហំផ្ទៃដី ប្រភេទឈើ និងបរិមាណឈើត្រូវប្រមូលផល
- មធ្យោបាយ និងឧបករណ៍ប្រើប្រាស់សម្រាប់ប្រតិបត្តិការប្រមូលផល។
- លេខវិញ្ញាបនប័ត្រ និងកាលបរិច្ឆេទដែលបានចុះបញ្ជី

**ប្រការ ៦**.-

ដើម្បីធានាបាននូវសុវត្ថិភាពការងារ មុនពេល និងក្នុងពេលប្រតិបត្តិការប្រមូលផលឈើ ម្ចាស់ព្រៃឯកជនត្រូវរៀបចំ ដូចជាប្រព័ន្ធផ្លូវ ទីលានគំនរឈើ ការកាប់រំលំ ការអូសទាញ និងការដឹកជញ្ជូន។

- អនុវត្តតាមបទដ្ឋានបច្ចេកទេស រួមមាន ប្រតិបត្តិការកាប់រំលំ ការអូសទាញ ការដឹកជញ្ជូន និងការគរជាគំនរឱ្យបានត្រឹមត្រូវ ដើម្បីរក្សាបានសណ្តាប់ធ្នាប់សាធារណៈ និងរួមចំណែកថែរក្សាបរិស្ថាន-សង្គម
- ទទួលខុសត្រូវ និងមានវិធានការប្រុងប្រយ័ត្នខ្ពស់ចំពោះការខូចខាតដោយ ឧបទ្ទវហេតុណាមួយដូចជា បង្កឱ្យមានភ្លើងឆេះព្រៃ និងបង្កគ្រោះថ្នាក់ផ្សេងៗ ។

**ប្រការ ៧**.-

ក្នុងករណីផ្អាកប្រតិបត្តិការប្រមូលផលឈើ ជាបណ្តោះអាសន្ន ម្ចាស់ព្រៃឯកជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ខណ្ឌរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចសាមី ដោយបញ្ជាក់នូវមូលហេតុ និងកាលរិច្ឆេទប្រតិបត្តិការប្រមូលផលឈើជាថ្មី។

**ប្រការ ៨**.-

ក្រោយពេលបញ្ចប់ប្រតិបត្តិការប្រមូលផលឈើ ម្ចាស់ព្រៃឯកជនត្រូវ៖

- ធ្វើអនាម័យ សំអាតទីតាំង របស់ខ្លួនឱ្យបានសមស្រប
- ផ្តល់ព័ត៌មានអំពីបរិមាណផលឈើជាក់ស្តែងជាលាយលក្ខណ៍អក្សរមកខណ្ឌរដ្ឋបាលព្រៃឈើសាមី ។

**ប្រការ ៩**.-

ការដឹកជញ្ជូនផល ព្រៃឈើចេញពីព្រៃឯកជន ឆ្ពោះទៅកាន់ទីផ្សារក្នុងស្រុកដូចជារោងចក្រ សិប្បកម្មកែច្នៃ ទីកន្លែងសន្និធិនានា ពុំតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនឡើយ ប៉ុន្តែម្ចាស់ព្រៃឯកជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ខណ្ឌរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចសាមី ឱ្យបានជ្រាបអំពីសកម្មភាពនេះយ៉ាងតិច០៣(បី)ថ្ងៃ មុនកាលបរិច្ឆេទដឹកជញ្ជូនចេញ។

**ប្រការ ១០**.-

ម្ចាស់ព្រៃឯកជនត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ក្នុងការចុះពិនិត្យ និងផ្ទៀងផ្ទាត់រាល់សកម្មភាព ការធ្វើអាជីវកម្មប្រមូលផល ឈើក្នុងករណីចាំបាច់។

## ផ្នែកទី៤
## កាតព្វកិច្ចម្ចាស់ព្រៃឯកជន

**ប្រការ ១១**.-

ម្ចាស់ព្រៃឯកជនមានកាតព្វកិច្ចកត់ត្រាចុះក្នុងសៀវភៅបន្ទុកព្រៃឯកជនប្រចាំខែនីមួយៗ នៅក្នុងឆ្នាំប្រតិបត្តិការ ដូចខាងក្រោម៖

**១-កំណត់ត្រាដំណើរការបង្កើតព្រៃឯកជន៖** រួមមានសកម្មភាពចាប់ផ្តើមពីការរៀបចំទីកន្លែងថ្នាលបណ្តុះ ការបំប៉នកូនឈើ ការដាំដុះនៅលើចម្ការ ការថែទាំ ការអនុវត្ត បច្ចេកទេសរុក្ខវប្បកម្មលើដំណុះព្រៃរហូតដល់ដំណាក់កាលមុនពេលប្រមូលផល (ឧបសម្ព័ន្ធ១)។

**២-កត់ត្រាដំណើរការអាជីវកម្មប្រមូលផលព្រៃឯកជន** រួមមាន កាលបរិច្ឆេទ ប្រភេទឈើ ទីតាំង ទំហំផ្ទៃដី និងបរិមាណផលប្រមូលបាន ប្រភេទឈើ បរិមាណដឹកជញ្ជូនចេញទៅទិសដៅប្រើប្រាស់។ល។ (ឧបសម្ព័ន្ធ២)

**ប្រការ ១២**.-

ម្ចាស់ព្រៃឯកជនត្រូវគោរព និងអនុវត្តតាមខ្លឹមសារនៃសៀវភៅបន្ទុកនេះ ព្រមទាំងបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ម្ចាស់ព្រៃឯកជនត្រូវទទួលខុសត្រូវចំពោះរាល់បទល្មើស ដែលអាចកើតមានឡើងនៅក្នុងដែនព្រៃឯកជនសាមី។

## ផ្នែកទី៥
## កន្លែងតម្កល់ឯកសារ

**ប្រការ ១៣**.-

សៀវភៅបន្ទុកព្រៃឯកជន ត្រូវបានរៀបចំចំនួន ០៤ច្បាប់ ដែលតម្កល់ទុកនៅ៖

| | |
|---|---|
| -រដ្ឋបាលព្រៃឈើ | ចំនួន ០១ច្បាប់ |
| -នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន | ចំនួន ០១ច្បាប់ |
| -ខណ្ឌរដ្ឋបាលព្រៃឈើសាមី | ចំនួន ០១ច្បាប់ |
| -ម្ចាស់ព្រៃឯកជន | ចំនួន ០១ច្បាប់។ |

**ប្រការ ១៣**.-

ម្ចាស់ព្រៃឯកជនបានអាន និងយល់ច្បាស់នូវខ្លឹមសារនៃសៀវភៅបន្ទុកព្រៃឯកជននេះហើយសន្យាថាគោរព និងអនុវត្តតាមបទប្បញ្ញត្តិនៃសៀវភៅបន្ទុកនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ.........................ខែ........... ឆ្នាំ............ ព.ស.២៥.......

...................... ថ្ងៃទី..........ខែ.........ឆ្នាំ២០.......

**ម្ចាស់ព្រៃឯកជន**

**បានឃើញ**

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលព្រៃឈើ**

## ឧបសម្ព័ន្ធ ១
## កំណត់ត្រា ដំណើរការប្រមូលផលព្រៃឯកជន

| ល.រ | កាលបរិច្ឆេទ | ប្រភេទឈើ | ទីតាំងឡូត៍ | ទំហំផ្ទៃដី | បរិមាណឈើ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ថ្ងៃ............................ខែ............ ឆ្នាំ............. ព.ស.២៥........

........................ ថ្ងៃទី...........ខែ..........ឆ្នាំ២០........

**ហត្ថលេខា ឬស្នាមមេដៃ(ម្ចាស់ព្រៃឯកជន)**

## ឧបសម្ព័ន្ធ ២

## កំណត់ត្រាសកម្មភាពអាជីវកម្មប្រមូលផលព្រៃឯកជន

| ល.រ | កាលបរិច្ឆេទ | ប្រភេទឈើ | បរិមាណ<br>ដឹកជញ្ជូន | ទិសដៅ<br>ដឹកជញ្ជូន | គោលដៅប្រើប្រាស់ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ថ្ងៃ............................ខែ............ ឆ្នាំ............. ព.ស.២៥........

........................ ថ្ងៃទី...........ខែ..............ឆ្នាំ២០........

**ហត្ថលេខា ឬស្នាមមេដៃ(ម្ចាស់ព្រៃឯកជន)**






រដ្ឋបាលព្រៃឈើ

#៤០, មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ